ក

# មាតិកា

## I-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម


០៩-៦-២០១៣ -ព្រះរាជក្រម នស/រកម/០៦១៣/០១១ ស្តីពី ស្តីពីការអនុម័តយល់ព្រមលើពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហេ្សណា ស្តីពីជីវសុវត្ថិភាព ៥៦៧២


### ២-ព្រះរាជក្រឹត្យ


០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨០ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូននាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ០៦ រូប ៥៦៩៦

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨១ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ឆាយ គីមសួន** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៦៩៧

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨២ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោក **សុខណ្ណា ពិសាខា** នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួង មហាផ្ទៃ ៥៦៩៨

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៣ ស្តីពី ការដំឡើងឋានន្តរស័ក្តិ ថ្នាក់ ឧត្តមសេនីយ៍ត្រី ជូនលោកវរសេនីយ៍ឯក **អ៊ិន សាខុធ** នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រី នគរបាលជាតិកម្ពុជា នៃក្រសួង មហាផ្ទៃ ៥៦៩៩

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **រីសេ ដឺនីស** (DENIS RICHER) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅសារ៉ង់តុង ឡឺប៉ុង (Charenton-LePont) សាធារណរដ្ឋបារាំង ៥៧០០

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៥ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **វ៉េន ម៉ៃខល វេចមេន** (WAYNE MICHAEL WEIGHTMAN) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅញូវអ៊ីហ្គល រដ្ឋផេនស៊ីលវេននីញ៉ា សហរដ្ឋអាមេរិក ដោយប្តូរឈ្មោះជា **គីម តារា** (KIM DARA) ៥៧០១

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ប្រេដលីយ ហ្គីល ហ្គែនណឺ (BRADLEY GILES GARNER) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតនៅទីក្រុងអូហ្គូស្តា រដ្ឋចចារ សហរដ្ឋអាមេរិក ៥៧០២

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សរុប ចំនួន ២៣ រូប ៥៧០៣

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សរុប ចំនួន ៥១ រូប ៥៧០៤

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៨៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៣ រូប ៥៧០៦

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ សប្បុរសជន ចំនួន ០២ រូប ៥៧០៧

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩១ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោក **សរ ខុន្ថា** ៥៧០៨

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩២ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ក្រុមប្រឹក្សាភិបាលអាណត្តិទី ៤ មន្ត្រីត្រួតពិនិត្យរដ្ឋ អមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចំនួន ០៩ រូប ៥៧០៩

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៣ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ សប្បុរសជន ចំនួន ០៣ រូប ៥៧១០

០៣-៦-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៦១៣/៥៩៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ លោកស្រី **Le Nu Thuy Duong** ៥៧១១

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

៣០-៥-២០១៣ -អនុក្រឹត្យលេខ ២៨៥ អនក្រ.បក ស្តីពី ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក ៥៧១២

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៨៦ អនក្រ.បក ស្តីពី បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ៥៧១៥

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៨៧ អនក្រ.បក ស្តីពី បែបបទ និងនីតិវិធីនៃការសុំសញ្ជាតូបនីយកម្ម ៥៧១៩

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៨៨ អនក្រ.បក ស្តីពី នីតិវិធី និងលក្ខខណ្ឌនៃការសុំលះបង់ សញ្ជាតិខ្មែរ ៥៧២៣

៣១-៥-២០១៣ -អនុក្រឹត្យលេខ ២៨៩ អនក្រ.បក ស្តីពី ការគ្រប់គ្រងសន្តិសុខឯកជន ៥៧២៦

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៣២

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៧៩ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ ៥៧៣៤

២៩-៣-២០១៣ -អនុក្រឹត្យលេខ ៣៨០ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ៥៧៣៦

០១-៤-២០១៣ -អនុក្រឹត្យលេខ ៣៨១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៣៨

០១-៤-២០១៣ -អនុក្រឹត្យលេខ ៣៨២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៣៩

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៣ អនក្រ.តត ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ ៥៧៤១

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៤ អនក្រ.តត ស្តីពី ការជូនគ្រឿងឥស្សរិយយស ៥៧៤៤

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៧៤៥

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៦ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៤៧

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៧៤៨

០២-៤-២០១៣ -អនុក្រឹត្យលេខ ៣៨៨ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៥៧៤៩

## ២_សារាចរ

២៩-៥-២០១៣ -សារាចរលេខ ០៣ សរ ស្តីពី ការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធី និងវិធានការ តាក់តែងសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ៥៧៥០

# ព្រះរាជក្រម

នស/រកម/០៦១៣/០៦១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំលើកទី៣ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME DU CAMBODGE … PALAIS ROYAL

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមលើពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាត ទៅនឹងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហ្សេណា ស្តីពីជីវសុវត្ថិភាព ដែលធ្វើនៅទីក្រុងណាហ្គោយ៉ា ប្រទេសជប៉ុន នាថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១០ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តពិធីសារបន្ថែមនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០១៣

នស/រកម/០៦១៣/០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត លេខ: ៥៩២ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

ស៊ុយ សុខា

# ពិធីសារបន្ថែម ណាហ្គោយ៉ា-កូឡាឡាំពួរ
# ស្តីពី
# ការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាត
# ទៅនឹងពិធីសារការតាហេ្សណាស្តីពីជីវសុវត្ថិភាព

ភាគីទៅនឹងពិធីសារបន្ថែមនេះ

ក្នុងនាមជាភាគីទៅនឹងពិធីសារកាតាហេ្សណា ស្តីពីជីវសុវត្ថិភាព ទៅនឹងអនុសញ្ញា ស្តីពីជីវៈចម្រុះ ត្រូវបានហៅថា "ពិធីសារ" ។

ដោយឈរលើគោលការណ៍ទី១៣ នៃសេក្តីថ្លែងការណ៍នៅទីក្រុងរីយ៉ូ ស្តីពីបរិស្ថាន និងការអភិវឌ្ឍ។

ដោយអះអាងជាថ្មីនូវអភិក្រមប្រុងប្រយ័ត្នជាមុន ដែលបានចែងក្នុងគោលការណ៍ទី ១៥ នៃសេចក្តីថ្លែងការណ៍នៅទីក្រុងរីយ៉ូ ស្តីពីបរិស្ថាន និងការអភិវឌ្ឍន៍។

ដោយទទួលស្គាល់ពីតម្រូវការផ្តល់នូវវិធានការឆ្លើយតបសមស្របនៅទីកន្លែង ដែលមានការខូចខាត ឬលទ្ធភាពដែលអាចកើតមានការខូចខាតគ្រប់គ្រាន់ ស្របតាមខ្លឹមសារនៃពិធីសារ។

យោងលើមាត្រា២៧ នៃពិធីសារ បានឯកភាពដូចតទៅ ៖

## មាត្រា ១
## គោលបំណង

គោលបំណងនៃពិធីសារបន្ថែមនេះ គឺដើម្បីរួមចំណែកដល់ការអភិរក្ស និងប្រើប្រាស់ ដោយនិរន្តរភាពនៃជីវៈចម្រុះ ដោយយកចិត្តទុកដាក់ពីហានិភ័យលើសុខភាពមនុស្ស តាមរយៈការផ្តល់នូវនីតិវិធី និងច្បាប់អន្តរជាតិលើការទទួលខុសត្រូវផ្នែកច្បាប់និងសំណងការខូចខាតទាក់ទងទៅនឹងសារពាង្គកាយកែច្នៃរស់។

## មាត្រា ២
## ការប្រើប្រាស់វាក្យស័ព្ទ

១. វាក្យស័ព្ទ ដែលបានប្រើក្នុងមាត្រា២នៃអនុសញ្ញា ស្តីពីជីវៈចម្រុះ ចាប់ពីពេលនេះតទៅហៅថា "អនុសញ្ញា" និងក្នុងមាត្រា៣នៃពិធីសារត្រូវយកមកប្រើក្នុងពិធីសារបន្ថែមនេះដែរ។

២. វាក្យស័ព្ទ លើសពីនេះត្រូវបានប្រើប្រាស់ក្នុងពិធីសារបន្ថែមនេះ ៖

(ក) "សន្និសីទនៃភាគី ដែលធ្វើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារ" មានន័យថា ជាសន្និសីទនៃភាគី ទៅនឹងអនុសញ្ញាធ្វើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារ។

(ខ) "ការខូចខាត" សំដៅដល់ផលប៉ះពាល់អវិជ្ជមានមកលើការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តរភាពនៃជីវៈចម្រុះ ដោយយកចិត្តទុកដាក់ដល់ហានិភ័យមកលើសុខភាពមនុស្ស ៖

(១) អាចវាស់វែងបាន ឬមើលឃើញជាក់ស្តែង នៅពេលណាដែលព័ត៌មានបឋមខាងវិទ្យាសាស្ត្រ ត្រូវបានបង្កើតឡើង ទទួលស្គាល់ដោយអាជ្ញាធរមានសមត្ថកិច្ចដែលគិតគូរដល់បម្រែបម្រួល ប៉ះពាល់លើមនុស្សនិងបម្រែបម្រួលធម្មជាតិ និង

(២) មានសារៈសំខាន់ដូចបានចែងក្នុងកថាខ័ណ្ឌទី៣ខាងក្រោម

(គ) "ប្រតិបត្តិករ" សំដៅដល់រូបវន្តបុគ្គលណាពាក់ព័ន្ធក្នុងការត្រួតពិនិត្យ ដោយផ្ទាល់ ឬប្រយោលនៃសារពាង្គកាយកែច្នៃរស់ ដែលអាចរួមបញ្ចូលទាំងអ្នកកាន់លិខិតអនុញ្ញាត ដែលបានដាក់លក់សារពាង្គកាយកែច្នៃរស់នៅលើទីផ្សារ អ្នកបង្កើត អ្នកផលិត ភាគីនាំចេញ អ្នកនាំចេញ អ្នកនាំចូល អ្នកកាន់ ឬអ្នកផ្គត់ផ្គង់បានកំណត់ក្នុងច្បាប់ជាតិ។

(ឃ) "វិធានការឆ្លើយតប" សំដៅដល់សកម្មភាពសមស្រប ដើម្បី ៖

(១) ការពារ កាត់បន្ថយជាអប្បបរមា ធ្វើការហ៊ុំព័ទ្ធ ធ្វើការកាត់បន្ថយ ឬជៀសអោយផុតពី ការខូចខាត អោយបានសមស្រប

(២) ស្តារជីវៈចម្រុះ តាមរយៈសកម្មភាពនឹងត្រូវអនុវត្តន៍តាមលំដាប់លំដោយដូចតទៅ ៖

(ក) ធ្វើការស្តារនៃជីវៈចម្រុះ អោយដូចសភាពដើមដែលមានមុនការខូចខាតបានកើតឡើង ឬការស្តារអោយបានសមមូលគ្នា និងស្តារដល់កម្រិតណាមួយដែលអាជ្ញាធរកំណត់ថាធ្វើលែងទៅមុខទៀតបាន

(ខ) ធ្វើការស្តារដោយជំនួសមកវិញនូវការបាត់បង់ជីវៈចម្រុះ និងសភាពដើមរបស់វានៅពេលតែមួយ ឬប្រភេទនៃការប្រើប្រាស់ដទៃទៀតនៅពេលតែមួយ ឬអោយបានសមស្របនៅលើភូមិសាស្ត្រផ្សេងៗ។

៣. ផលប៉ះពាល់អវិជ្ជមាន "ធ្ងន់ធ្ងរ" នឹងត្រូវកំណត់ដោយឈរលើកត្តា ដូចជា ៖

(ក) ការផ្លាស់ប្តូរជាអចិន្ត្រៃយ៍ ឬក្នុងរយៈពេលវែងនឹងត្រូវបានចាត់ទុកថាជាការផ្លាស់ប្តូរដែលមិនអាចកែប្រែឡើងវិញ តាមរយៈការស្តារតាមលក្ខណៈធម្មជាតិ នៅក្នុងរយៈពេលសមស្របណាមួយ

(ខ) ទំហំនៃការប្រែប្រួលផ្នែកបរិមាណ ឬគុណភាពដែលប៉ះពាល់ជាអវិជ្ជមានលើសមាសភាពជីវៈចម្រុះ

(គ) ការកាត់បន្ថយនៃសមាសភាពជីវៈចម្រុះ ដើម្បីផ្តល់ទំនិញ និងសេវាកម្ម

(ឃ) ទំហំនៃផលប៉ះពាល់អវិជ្ជមានលើសុខភាពមនុស្សនៅក្នុងបរិបទនៃពិធីសារ។

## មាត្រា ៣
## វិសាលភាព

១. ពិធីសារបន្ថែមនេះ អនុវត្តលើការខូចខាត ឬបណ្តាលមកពីសារពាង្គកាយកែច្នៃរស់ ដែលបានពិពណ៌នា សំដៅដល់ ៖

(ក) សារពាង្គកាយកែច្នៃរស់ ដែលយកមកប្រើប្រាស់ដោយផ្ទាល់ ជាចំណីអាហារ ចំណីសត្វ ឬសម្រាប់ធ្វើការកែច្នៃ

(ខ) សារពាង្គកាយកែច្នៃរស់ មានគោលដៅសម្រាប់ប្រើប្រាស់ក្នុងមន្ទីរពិសោធន៍

(គ) សារពាង្គកាយកែច្នៃរស់ មានគោលបំណងដោយចេតនាដាក់ក្នុងបរិស្ថាន។

២. ទាក់ទងនឹងចលនាឆ្លងដែនអន្តរជាតិ ពិធីសារបន្ថែមនេះ អនុវត្តលើការខូចខាត បណ្តាលមកពីការប្រើប្រាស់សារពាង្គកាយកែច្នៃរស់ ដែលត្រូវបានអនុញ្ញាតដូចបានចែង ក្នុងកថាខ័ណ្ឌទី១ ខាងលើ។

៣. ពិធីសារបន្ថែមនេះអនុវត្តផងដែរលើការខូចខាតបណ្តាលមកពីចលនាឆ្លងដែនអចេតនាដូចមានចែងក្នុងមាត្រា១៧នៃពិធីសារព្រមទាំងការខូចខាតបណ្តាលមកពីចលនាឆ្លងដែនល្មើសច្បាប់ មានចែងក្នុងមាត្រា២៥ នៃពិធីសារ។

៤. ពិធីសារបន្ថែមនេះអនុវត្តលើការខូចខាតបណ្តាលមកពីចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ដែលគិតចាប់ពីការចូលជាធរមាននៃពិធីសារបន្ថែមនេះសម្រាប់ភាគីដែលមានយុត្តាធិការលើចលនាឆ្លងដែន។

៥. ពិធីសារបន្ថែមនេះអនុវត្តលើការខូចខាតដែលបានកើតឡើងក្នុងតំបន់នៃព្រំដែន យុត្តាធិការជាតិរបស់ភាគី។

៦. ភាគីនានាអាចប្រើប្រាស់លក្ខខណ្ឌិកៈដែលបានកំណត់នៅក្នុងច្បាប់ជាតិដើម្បីដោះស្រាយការខូចខាតដែលកើតនៅក្នុងព្រំដែននៃយុត្តាធិការជាតិរបស់គេ។

៧. ច្បាប់ជាតិដែលអនុវត្តពិធីសារបន្ថែមនេះ ត្រូវអនុវត្តផងដែរលើការខូចខាតបណ្តាលមកពីចលនាឆ្លងដែននៃសារពាង្គកាយកែច្នៃរស់ ពីបណ្តាប្រទេសមិនមែនជាភាគី។

## មាត្រា ៤
## សហេតុកម្ម

ត្រូវបង្កើតទំនាក់ទំនងហេតុផលមួយរវាងការខូចខាត និងសារពាង្គកាយកែច្នៃរស់ដែលជាបញ្ហាត្រូវដោះស្រាយ អនុលោមតាមច្បាប់ជាតិ។

## មាត្រា ៥
## វិធានការឆ្លើយតប

១. ក្នុងព្រឹត្តការណ៍កើតមានការខូចខាត ភាគីនានាត្រូវតម្រូវអោយប្រតិបត្តិករមួយ ឬច្រើន ផ្អែកតាមការកំណត់ ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បី ៖

(ក) ជូនដំណឹងជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ច

(ខ) វាយតម្លៃការខូចខាត និង

(គ) ចាត់វិធានការឆ្លើយតប។

២. អាជ្ញាធរមានសមត្ថកិច្ចត្រូវ ៖

(ក) ធ្វើអត្តសញ្ញាណប្រតិបត្តិករ ដែលបណ្តាលអោយមានការខូចខាត

(ខ) វាយតម្លៃការខូចខាត និង

(គ) កំណត់វិធានការឆ្លើយតបណាមួយ ដែលប្រតិបត្តិករគួរយកមកអនុវត្តន៍។

៣. នៅទីកន្លែងណាដែលមានព័ត៌មានពាក់ព័ន្ធ រួមទាំងវត្តមានព័ត៌មានវិទ្យាសាស្ត្រ ឬ ព័ត៌មានដែលមានក្នុងបណ្តាញផ្សព្វផ្សាយព័ត៌មានជីវសុវត្ថិភាព ដែលបញ្ជាក់ថាមាន លទ្ធភាពគ្រប់គ្រាន់ ដែលនឹងបណ្តាលអោយមានការខូចខាតប្រសិនពុំបានចាត់ វិធានការ ឆ្លើយតបទាន់ពេលវេលា ដូចនេះត្រូវតម្រូវអោយប្រតិបត្តិករចាត់វិធានការ ដើម្បីគេចជៀសពីការខូចខាតទាំងនោះ។

៤. អាជ្ញាធរមានសមត្ថកិច្ច អាចអនុវត្តវិធានការឆ្លើយតបសមស្រប ជាពិសេសក្នុងករណីនៅពេលដែលប្រតិបត្តិករខកខានពុំបានចាត់វិធានការ។

៥. អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិទទួលបានមកវិញពីប្រតិបត្តិករនូវថ្លៃដើម និងការចំណាយដែលកើតឡើងដោយចៃដន្យទាក់ទងនឹងការវាយតម្លៃនៃការខូចខាត និងការអនុវត្តវិធានការឆ្លើយតបទាំងនោះអោយបានសមស្រប។ ភាគីនានាអាចចែងនៅក្នុងច្បាប់ជាតិរបស់ខ្លួនដោយអាស្រ័យតាមស្ថានភាពដទៃទៀត ដែលប្រតិបត្តិករអាចមិនតម្រូវអោយទទួលបន្ទុកសងថ្លៃដើមនិងការចំណាយ។

៦. សេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ដែលតម្រូវអោយប្រតិបត្តិករចាត់វិធានការឆ្លើយតប គួរមានហេតុផលត្រឹមត្រូវ។ សេចក្តីសម្រេចនោះ គួរជូនដំណឹងដល់ប្រតិបត្តិករ។ ច្បាប់ជាតិត្រូវចែងអំពីសំណងរួមទាំងកាលានុវត្តភាពសម្រាប់ការត្រួតពិនិត្យផ្នែកតុលាការ និងរដ្ឋបាលនៃសេចក្តីសម្រេចនោះ។ អនុលោមតាមច្បាប់ជាតិ អាជ្ញាធរមានសមត្ថកិច្ចត្រូវជូនដំណឹងដល់ប្រតិបត្តិករផងដែរពីមធ្យោបាយសំណងដែលអាចធ្វើទៅបាន។ បណ្តឹងសើរើទៅនឹងមធ្យោបាយសំណងនោះ មិនត្រូវរារាំងអាជ្ញាធរមានសមត្ថកិច្ចពីការចាត់វិធានការឆ្លើយតបនោះ ក្នុងកាលៈទេសៈសមស្របឡើយ ប្រសិនបើច្បាប់ជាតិមិនបានចែង។

៧. ក្នុងការអនុវត្តមាត្រានេះ និងដោយមានទស្សនៈលើការកំណត់អត្ថន័យនៃវិធានការឆ្លើយតបជាក់លាក់ ដើម្បីតម្រូវអោយអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការ ភាគីនានាអាចវាយតម្លៃអោយសមស្របថាតើវិធានការឆ្លើយតបទាំងនោះ ត្រូវបានចែងក្នុងច្បាប់ជាតិ ហើយ ឬនៅ ស្តីពីការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។

៨. ត្រូវអនុវត្តវិធានការឆ្លើយតបដោយអនុលោមតាមច្បាប់ជាតិ។

## មាត្រា ៦
## អញ្ញត្រកម្ម

១. ក្នុងច្បាប់ជាតិ ភាគីនានាអាចចែងអំពីអញ្ញត្រកម្ម ដូចខាងក្រោម ៖

(ក) គ្រោះមហន្តរាយធម្មជាតិ

(ខ) សង្គ្រាម ឬការបះបោរក្នុងសង្គម

២. ក្នុងច្បាប់ជាតិ ភាគីនានាអាចចែងអំពីអញ្ញត្រកម្មដទៃទៀត ឬការកាត់បន្ថយតាមដែលភាគីអាចពិចារណាធ្វើទៅបាន។

## មាត្រា ៧
## ការកំណត់ពេលវេលា

យោងតាមច្បាប់ជាតិ ភាគីនានាអាចផ្តល់នូវ ៖

(ក) ពេលវេលាកំណត់ច្បាស់លាស់ ឬពេលវេលាប្រហាក់ប្រហែលរួមទាំងសកម្មភាពទាក់ទងនឹងវិធានការឆ្លើយតប និង

(ខ) ការចាប់ផ្តើមនៃរយៈពេលដែលបានកំណត់។

## មាត្រា ៨
## ការកម្រិតហិរញ្ញប្បទាន

ក្នុងច្បាប់ជាតិ ភាគីនានាអាចចែងអំពីការកម្រិតហិរញ្ញប្បទាន សម្រាប់ទូទាត់លើថ្លៃដើម និងការចំណាយទាក់ទងនឹងវិធានការឆ្លើយតប។

## មាត្រា ៩
## សិទ្ធិនៃបណ្តឹងសើរើ

ពិធីសារបន្ថែមនេះ មិនកំណត់ព្រំដែន ឬដាក់កំហិតដល់សិទ្ធិសើរើ ឬសំណងដែល ប្រតិបត្តិករអាចជំទាស់ទៅនឹងបុគ្គលណាមួយ។

## មាត្រា ១០
## ការធានាផ្នែកហិរញ្ញប្បទាន

១. ភាគីនានារក្សាសិទ្ធិដើម្បីចែងនៅក្នុងច្បាប់ជាតិអំពីការធានាដល់ផ្នែកហិរញ្ញប្បទាន

២. ភាគីនានាត្រូវអនុវត្តសិទ្ធិ ដូចមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើ ដើម្បីអោយមាន សង្គតិភាពជាមួយសិទ្ធិនិងកាតព្វកិច្ចនៅក្រោមច្បាប់អន្តរជាតិដោយគិតគូរពីកថាខ័ណ្ឌចុងក្រោយចំនួន៣ របស់ពិធីសារ។

៣. កិច្ចប្រជុំទី១ របស់សិន្និសីទនៃភាគីធ្វើជាកិច្ចប្រជុំភាគីទៅនឹងពិធីសារ បន្ទាប់ពីពិធីសារបន្ថែមនេះចូលជាធរមាន ត្រូវស្នើលេខាធិការដ្ឋានដើម្បីរៀបចំធ្វើការសិក្សាអោយ ទូលំទូលាយ ដែលត្រូវផ្តោតលើបញ្ហាដូចខាងក្រោមក្នុងចំណោមបញ្ហាដទៃទៀត ៖

(ក) គំរូនៃយន្តការធានាហិរញ្ញប្បទាន

(ខ) ការវាយតម្លៃនៃផលប៉ះពាល់សង្គម និងបរិស្ថាននៃយន្តការនោះ ជាពិសេសក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និង

(គ) អត្តសញ្ញាណកម្មនៃអង្គភាពសមស្របដើម្បីផ្តល់ការធានាផ្នែកហិរញ្ញប្បទាន។

## មាត្រា ១១
## ការទទួលខុសត្រូវរបស់រដ្ឋសម្រាប់
## សកម្មភាពល្មើសច្បាប់អន្តរជាតិ

ពិធីសារបន្ថែមនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋនៅក្រោមបរិធានច្បាប់អន្តរជាតិទាក់ទងនឹងការទទួលខុសត្រូវរបស់រដ្ឋ សម្រាប់សកម្មភាពល្មើសច្បាប់អន្តរជាតិ។

## មាត្រា ១២
## ការអនុវត្ត និងទំនាក់ទំនងនឹង
## ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

១.ភាគីនានាគួរតែចែងនៅក្នុងច្បាប់ជាតិរបស់ខ្លួននូវបរិធានច្បាប់ និងនីតិវិធីសម្រាប់ ដោះស្រាយការខូចខាត។ ដើម្បីអនុវត្តកាតព្វកិច្ចនេះអោយបានសមស្រប ភាគីនានាត្រូវចាត់វិធានការឆ្លើយតប ដោយអនុលោមតាមពិធីសារបន្ថែមនេះ ដូចខាងក្រោម ៖

(ក) អនុវត្តនូវច្បាប់ជាតិដែលមានស្រាប់ ដោយរួមបញ្ចូលនូវបរិធានច្បាប់ទូទៅនិងនីតិវិធីមួយចំនួនដែលអាច អនុវត្តបានស្តីពីការទទួលខុសត្រូវសំណងរដ្ឋប្បវេណី

(ខ) អនុវត្ត ឬរៀបចំបរិធានច្បាប់ និងនីតិវិធីនានាលើការទទួលខុសត្រូវសំណងរដ្ឋប្បវេណី ដាច់ដោយឡែក សម្រាប់គោលបំណងនេះ ឬ

(គ) អនុវត្ត ឬរៀបចំបញ្ចូលគ្នានូវចំណុចទាំងពីរខាងលើ (ក) និង(ខ)។

២. ដោយមានគោលបំណងផ្តល់នូវបរិធាន និងនីតិវិធីនានាអោយបានសមស្រប ឬគ្រប់គ្រាន់ នៅក្នុងច្បាប់ជាតិ ស្តីពីការទទួលខុសត្រូវសំណងរដ្ឋប្បវេណី សម្រាប់ការខូចខាតរូប

រាងកាយ ឬសម្ភារៈ ដែលពាក់ព័ន្ធជាមួយការខូចខាត ដូចបានកំណត់នៅក្នុង មាត្រា២ កថាខ័ណ្ឌ ២ (ខ) ភាគីនានាត្រូវ ៖

(ក) បន្តអនុវត្តនូវច្បាប់ដែលមានស្រាប់ស្តីពីការទទួលខុសត្រូវសំណងរដ្ឋប្បវេណី

(ខ) រៀបចំ និងអនុវត្ត ឬបន្តអនុវត្តន៍ច្បាប់ស្តីពីការទទួលខុសត្រូវសំណងរដ្ឋប្បវេណីជាពិសេស សម្រាប់គោលបំណងនោះ ឬ

(គ) រៀបចំ និងអនុវត្ត ឬបន្តអនុវត្តន៍ចំនុច (ក) និង(ខ)។

៣. ក្នុងពេលកំពុងរៀបចំច្បាប់ស្តីពីការទទួលខុសត្រូវសំណងរដ្ឋប្បវេណី ដូចមានចែងក្នុងអនុកថា ខ័ណ្ឌ (ខ) ឬ(គ) នៃកថាខ័ណ្ឌ ១ ឬ២ ខាងលើ ភាគីនានា ត្រូវលើកយករាល់បញ្ហានីមួយៗ ក្នុងចំណោមបញ្ហាដទៃទៀតដូចខាងក្រោមមកដោះស្រាយអោយបានសមស្រប ៖

(ក) ការខូចខាត

(ខ) ស្តង់ដារនៃការទទួលខុសត្រូវ ដោយរួមទាំងការទទួលខុសត្រូវផ្អែកច្បាប់តឹងរឹង ឬការទទួលខុសត្រូវផ្អែកច្បាប់ផ្អែកលើកំហុសជាក់ស្តែង

(គ) ការដាក់បន្ទុកនៃការទទួលខុសត្រូវអោយបានសមស្រប

(ឃ) សិទ្ធិទាមទារសំណង។

## មាត្រា ១៣
## ការវាយតម្លៃ និងការកែសម្រួល

សន្និសីទរបស់ភាគី ដែលបម្រើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារ ត្រូវរៀបចំការកែសម្រួល ពីប្រសិទ្ធភាពនៃពិធីសារបន្ថែមនេះក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីការចូលជាធរមាន និងរៀងរាល់៥ឆ្នាំបន្ទាប់មក ភាគីនានាត្រូវផ្តល់ព័ត៌មាន ដែលបានធ្វើក្នុងការកែសម្រួលនោះ ។ ការកែសម្រួលត្រូវរៀបចំធ្វើឡើង នៅក្នុងបរិបទនៃការវាយតម្លៃ និងការកែសម្រួលនៃពិធីសារ និងដូចបានបញ្ជាក់នៅក្នុងមាត្រា៣៥ នៃពិធីសារ ប្រសិនបើ គ្មានសេចក្តីសម្រេចអនុម័តដោយភាគីទៅនឹងពិធីសារបន្ថែមនេះទេ។ ការការកែសម្រួលលើកដំបូងត្រូវរួមបញ្ចូលការកែសម្រួលនៃប្រសិទ្ធភាពក្នុងមាត្រា១០ និង១២។

## មាត្រា ១៤
## សន្និសីទនៃភាគីបម្រើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារ

១. យោងតាមកថាខ័ណ្ឌទី២ នៃមាត្រា៣២របស់អនុសញ្ញា សន្និសីទរបស់ភាគីបម្រើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារត្រូវធ្វើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារបន្ថែមនេះ

២. សន្និសីទរបស់ភាគី បម្រើជាកិច្ចប្រជុំរបស់ភាគីទៅនឹងពិធីសារ ត្រូវពិនិត្យមើលការកែសម្រួលការអនុវត្តនៃពិធីសារបន្ថែមនេះជាទៀងទាត់ ហើយស្របតាមអាណត្តរបស់ខ្លួន ហើយត្រូវធ្វើសេចក្តីសម្រេចចាំបាច់ ដើម្បីលើកកំពស់ការអនុវត្តអោយមានប្រសិទ្ធភាព។

សន្និសីទនេះត្រូវបំពេញមុខងារដែលបានចាត់តាំង ដែលបានកំណត់ដោយពិធីសារបន្ថែមនេះ នឹងមុខងារដោយបានធ្វើការផ្លាស់ប្តូរចាំបាច់ ដែលបានកំណត់ក្នុងកថាខ័ណ្ឌទី៤ (ក) និង(ច) នៃមាត្រា២៩ នៃពិធីសារ។

## មាត្រា ១៥
## លេខាធិការដ្ឋាន

លេខាធិការដ្ឋានត្រូវបានបង្កើតដោយមាត្រា២៤ នៃអនុសញ្ញា ត្រូវបម្រើជាលេខាធិការដ្ឋាននៃពិធីសារបន្ថែមនេះ។

## មាត្រា ១៦
## ទំនាក់ទំនងជាមួយអនុសញ្ញា និងពិធីសារ

១. ពិធីសារបន្ថែមនេះ ត្រូវធ្វើឯកសារបន្ថែមលើពិធីសារ និងមិនត្រូវកែសម្រួល ឬធ្វើវិសោធន៍កម្មពិធីសារទេ

២. ពិធីសារបន្ថែមនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃភាគីទៅនឹងពិធីសារបន្ថែមនេះនៅក្រោមអនុសញ្ញា និងពិធីសារ

៣. លើកលែងតែមានចែងនៅក្នុងពិធីសារបន្ថែមនេះ បញ្ញត្តិនានានៃអនុសញ្ញា និងពិធីសារត្រូវ អនុវត្តលើពិធីសារបន្ថែមនេះ ដោយបានធ្វើការផ្លាស់ប្តូរចាំបាច់

៤. ដោយមិនយោងទៅលើកថាខ័ណ្ឌទី៣ ខាងលើ ពិធីសារបន្ថែមមិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៅក្រោមច្បាប់អន្តរជាតិ។

## មាត្រា ១៧
## ការចុះហត្ថលេខា

ការចុះហត្ថលេខាលើពិធីសារបន្ថែមនេះ នឹងត្រូវរៀបចំធ្វើឡើងដោយភាគីទៅនឹងពិធីសារនៅឯទីស្នាក់អង្គការសហប្រជាជាតិ ក្នុងបុរីញូវយក ចាប់ពីថ្ងៃទី ៧ ខែមិនា ឆ្នាំ២០១១ ដល់ថ្ងៃទី ៦ ខែមិនា ឆ្នាំ២០១២ ។

## មាត្រា ១៨
## ការចូលជាធរមាន

១. ពិធីសារបន្ថែមនេះ ត្រូវចូលជាធរមានក្នុងរយៈពេល៩០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការតំកល់យុទ្ធោបករណ៍ទី៤០ នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលជាសមាជិករបស់រដ្ឋនានា ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលជាភាគីទៅនឹងពិធីសារ ។

២. ពិធីសារបន្ថែមនេះ ត្រូវចូលជាធរមានសម្រាប់រដ្ឋ ឬអង្គការសមាហរណកម្ម សេដ្ឋកិច្ច

ក្នុងតំបន់ ដែលផ្តល់សច្ចាប័នទទួលយក ឬអនុម័តពិធីសារបន្ថែម ឬចូលជា សមាជិក បន្ទាប់ពីបានតម្កល់យុទ្ធោបករណ៍ទី៨០ដូចមានចែងក្នុងកថាខ័ណ្ឌទី១ខាងលើ នៅថ្ងៃទី៩០ បន្ទាប់ពីកាលបរិច្ឆេទនៃបណ្ណារដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់តម្កល់យុទ្ធោបករណ៍របស់គេនៃការផ្តល់សច្ចាប័ន ការទទួលយក និងការអនុម័ត ឬការចូលជាសមាជិក ឬ នៅថ្ងៃដែលពិធីសារ ចូលជាធរមានសម្រាប់រដ្ឋឬអង្គការ សមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ដែលចូលជាធរមានចុងក្រោយគេ។

៣. សម្រាប់គោលបំណងនៃកថាខ័ណ្ឌទី១ និងទី២ខាងលើ អង្គការសមាហរណកម្ម សេដ្ឋកិច្ចក្នុង តំបន់ដែលបានតម្កល់យុទ្ធោបករណ៍ មិនត្រូវរាប់ថាជាការតម្កល់បន្ថែមដោយ រដ្ឋជាសមាជិកនៃអង្គការនោះឡើយ។

## មាត្រា ១៩
## ការលើកលែង

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ______

គ្មានការលើកលែងចែងនៅក្នុងពិធីសារនេះទេ។

## មាត្រា ២០
## ការដកសមាជិកភាព

១. នៅពេលណាក៏ដោយ បន្ទាប់ពីរយៈពេលពីរឆ្នាំ ដែលពិធីសារបន្ថែមនេះបានចូលជាធរមានសម្រាប់ភាគី ភាគីនោះអាចដកសមាជិកភាពចេញពីពិធីសារបន្ថែមនេះ ដោយផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរទៅការិយាល័យតម្កល់យុទ្ធោបករណ៍។

២. ការដកសមាជិកភាពនោះ ត្រូវកើតមានឡើងនៅពេលផុតកំណត់រយៈពេល១ឆ្នាំ នៃការទទួលរបស់ការិយាល័យយុទ្ធោបករណ៍ ឬក្នុងកំឡុងកាលបរិច្ឆេទបន្ទាប់ ដូចដែលអាចបញ្ជាក់ក្នុងសេចក្តីជូនដំណឹងនៃការដកសមាជិកភាព។

៣. ភាគីណាដែលដកសមាជិកភាពចេញពីពិធីសារ ដែលបានអនុលោមតាមមាត្រា៣៩ នឹងត្រូវចាត់ទុកថាដកសមាជិកភាពចេញពីពិធីសារបន្ថែមនេះផងដែរ។

## មាត្រា ២១
## ច្បាប់ដើម

ច្បាប់ដើមនៃពិធីសារបន្ថែមនេះ ដែលសរសេរជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

ដើម្បីជាសាក្សីក្នុងពិធីសារបន្ថែមនេះត្រូវបានផ្តល់សិទ្ធិស្របច្បាប់ដោយមានហត្ថលេខាលើពិធីសារបន្ថែមនេះ។

ធ្វើនៅទីក្រុង ណាហ្គោយ៉ា ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០។



# NAGOYA – KUALA LUMPUR SUPPLEMENTARY PROTOCOL ON LIABILITY AND REDRESS TO THE CARTAGENA PROTOCOL ON BIOSAFETY

# NAGOYA – KUALA LUMPUR SUPPLEMENTARY PROTOCOL ON LIABILITY AND REDRESS TO THE CARTAGENA PROTOCOL ON BIOSAFETY

SECRETARIAT OF THE CONVENTION
ON BIOLOGICAL DIVERSITY
MONTREAL

United Nations

Secretariat of the Convention on Biological Diversity
United Nations Environment Programme
413 St. Jacques Street West, Suite 800
Montreal, Quebec, Canada H2Y 1N9
Phone: +1 (514) 288 2220
Fax: +1 (514) 288 6588
E-mail: secretariat@cbd.int
Website: www.cbd.int and bch.cbd.int/protocol

© 2011 by the Secretariat of the Convention on Biological Diversity
All rights reserved. Published 2011
Printed in Canada
ISBN: 92-9225-324-7

This publication may be reproduced for educational or non-profit purposes without special permission from the copyright holders, provided acknowledgement of the source is made. The Secretariat of the Convention would appreciate receiving a copy of the publications that use this document as a source.

Local catalogue record:

Nagoya - Kuala Lumpur Supplementary Protocol on Liability and Redress to the Cartagena Protocol on Biosafety / Secretariat of the Convention on Biological Diversity.
Summary:" This booklet contains the Nagoya - Kuala Lumpur Supplementary Protocol on Liability and Redress to the Cartagena Protocol on Biosafety." — Provided by publisher.
ISBN 92-9225-324-7
1. Biodiversity – Law and legislation 2. Environmental law, International 3. Biodiversity—International cooperation 4. Biotechnology
I. Convention on Biological Diversity (1992). Protocols, etc., 2010 Oct 15. II. Conference of the Parties to the Convention on Biological Diversity serving as the meeting of the Parties to the Cartagena Protocol on Biosafety (2010 : Nagoya, Japan). III. United Nations.

For further information please contact the Secretariat of the Convention on Biological Diversity

## Introduction

The Cartagena Protocol on Biosafety was adopted on 29 January 2000 as a supplementary agreement to the Convention on Biological Diversity. It entered into force on 11 September 2003. The Protocol is a multilateral environmental agreement that is intended to contribute to the safe transfer, handling, and use of living modified organisms that may have adverse effects on biological diversity, taking also into account risks to human health, and with specific focus on transboundary movements.

The issue of elaborating rules on liability and redress for damage resulting from living modified organisms was under consideration internationally both before and after the adoption of the Protocol on Biosafety. Article 27 of the Protocol set the stage for the establishment of a formal process towards completion of the consideration of the issue within a defined timeframe. Article 27 required the Conference of the Parties to the Convention on Biological Diversity serving as the meeting of the Parties to the Biosafety Protocol to adopt, at its first meeting, a process with respect to the appropriate elaboration of international rules and procedures in the field of liability and redress for damage resulting from transboundary movements of living modified organisms.

Accordingly, the first meeting of the Conference of the Parties serving as the meeting of the Parties to the Cartagena Protocol on Biosafety which was held in Kuala Lumpur, from 23 to 27 February 2004 established an Ad Hoc Open-ended Working Group of Legal and Technical Experts on Liability and Redress in the Context of the Cartagena Protocol on Biosafety to analyse issues, elaborate options, and propose international rules and procedures on the subject.

After several years of negotiations, an international agreement, known as the Nagoya – Kuala Lumpur Supplementary Protocol on Liability and Redress to the Cartagena Protocol on Biosafety, was finalized and adopted in Nagoya, Japan, on 15 October 2010 at the fifth meeting of the Conference of the Parties serving as the meeting of the Parties to the Protocol.

The Supplementary Protocol adopts an administrative approach to addressing response measures in the event of damage or sufficient likelihood of damage to the conservation and sustainable use of biological diversity resulting from living modified organisms that find their origin in transboundary movements.

Like its parent treaty, the Cartagena Protocol on Biosafety, the adoption of the Nagoya – Kuala Lumpur Supplementary Protocol is seen as playing a function of preventing damage on the one hand and as a further confidence-building measure on the other, in the development and application of modern biotechnology. It advances the enabling

# NAGOYA – KUALA LUMPUR SUPPLEMENTARY PROTOCOL ON LIABILITY AND REDRESS TO THE CARTAGENA PROTOCOL ON BIOSAFETY

*The Parties to this Supplementary Protocol,*

*Being* Parties to the Cartagena Protocol on Biosafety to the Convention on Biological Diversity, hereinafter referred to as "the Protocol",

*Taking into account* Principle 13 of the Rio Declaration on Environment and Development,

*Reaffirming* the precautionary approach contained in Principle 15 of the Rio Declaration on Environment and Development,

*Recognizing* the need to provide for appropriate response measures where there is damage or sufficient likelihood of damage, consistent with the Protocol,

*Recalling* Article 27 of the Protocol,

Have agreed as follows:

## Article 1
## OBJECTIVE

The objective of this Supplementary Protocol is to contribute to the conservation and sustainable use of biological diversity, taking also into account risks to human health, by providing international rules and procedures in the field of liability and redress relating to living modified organisms.

## Article 2
## USE OF TERMS

1. The terms used in Article 2 of the Convention on Biological Diversity, hereinafter referred to as "the Convention", and Article 3 of the Protocol shall apply to this Supplementary Protocol.

2. In addition, for the purposes of this Supplementary Protocol:

(a) "Conference of the Parties serving as the meeting of the Parties to the Protocol" means the Conference of the Parties to the Convention serving as the meeting of the Parties to the Protocol;

(b) "Damage" means an adverse effect on the conservation and sustainable use of biological diversity, taking also into account risks to human health, that:

(i) Is measurable or otherwise observable taking into account, wherever available, scientifically-established baselines recognized by a competent authority that takes into account any other human induced variation and natural variation; and

(ii) Is significant as set out in paragraph 3 below;

(c) "Operator" means any person in direct or indirect control of the living modified organism which could, as appropriate and as determined by domestic law, include, *inter alia*, the permit holder, person who placed the living modified organism on the market, developer, producer, notifier, exporter, importer, carrier or supplier;

(d) "Response measures" means reasonable actions to:

(i) Prevent, minimize, contain, mitigate, or otherwise avoid damage, as appropriate;

(ii) Restore biological diversity through actions to be undertaken in the following order of preference:

a. Restoration of biological diversity to the condition that existed before the damage occurred, or its nearest equivalent; and where the competent authority determines this is not possible;

b. Restoration by, *inter alia*, replacing the loss of biological diversity with other components of biological diversity for the same, or for another type of use either at the same or, as appropriate, at an alternative location.

3. A "significant" adverse effect is to be determined on the basis of factors, such as:

(a) The long-term or permanent change, to be understood as change that will not be redressed through natural recovery within a reasonable period of time;

(b) The extent of the qualitative or quantitative changes that adversely affect the components of biological diversity;

(c) The reduction of the ability of components of biological diversity to provide goods and services;

(d) The extent of any adverse effects on human health in the context of the Protocol.

## Article 3
## SCOPE

1. This Supplementary Protocol applies to damage resulting from living modified organisms which find their origin in a transboundary movement. The living modified organisms referred to are those:

(a) Intended for direct use as food or feed, or for processing;

(b) Destined for contained use;

(c) Intended for intentional introduction into the environment.

2. With respect to intentional transboundary movements, this Supplementary Protocol applies to damage resulting from any authorized use of the living modified organisms referred to in paragraph 1 above.

3. This Supplementary Protocol also applies to damage resulting from unintentional transboundary movements as referred to in Article 17 of the Protocol as well as damage resulting from illegal transboundary movements as referred to in Article 25 of the Protocol.

4. This Supplementary Protocol applies to damage resulting from a transboundary movement of living modified organisms that started after the entry into force of this Supplementary Protocol for the Party into whose jurisdiction the transboundary movement was made.

5. This Supplementary Protocol applies to damage that occurred in areas within the limits of the national jurisdiction of Parties.

6. Parties may use criteria set out in their domestic law to address damage that occurs within the limits of their national jurisdiction.

7. Domestic law implementing this Supplementary Protocol shall also apply to damage resulting from transboundary movements of living modified organisms from non-Parties.

## Article 4
## CAUSATION

A causal link shall be established between the damage and the living modified organism in question in accordance with domestic law.

## Article 5
## RESPONSE MEASURES

1. Parties shall require the appropriate operator or operators, in the event of damage, subject to any requirements of the competent authority, to:

(a) Immediately inform the competent authority;

(b) Evaluate the damage; and

(c) Take appropriate response measures.

2. The competent authority shall:

(a) Identify the operator which has caused the damage;

(b) Evaluate the damage; and

(c) Determine which response measures should be taken by the operator.

3. Where relevant information, including available scientific information or information available in the Biosafety Clearing-House, indicates that there is a sufficient likelihood that damage will result if timely response measures are not taken, the operator shall be required to take appropriate response measures so as to avoid such damage.

4. The competent authority may implement appropriate response measures, including, in particular, when the operator has failed to do so.

5. The competent authority has the right to recover from the operator the costs and expenses of, and incidental to, the evaluation of the damage and the implementation of any such appropriate response measures. Parties may provide, in their domestic law, for other situations in which the operator may not be required to bear the costs and expenses.

6. Decisions of the competent authority requiring the operator to take response measures should be reasoned. Such decisions should be notified to the operator. Domestic law shall provide for remedies, including the opportunity for administrative or judicial review of such decisions. The competent authority shall, in accordance with domestic law, also inform the operator of the available remedies. Recourse to such remedies shall not impede the competent authority from taking response measures in appropriate circumstances, unless otherwise provided by domestic law.

7. In implementing this Article and with a view to defining the specific response measures to be required or taken by the competent authority, Parties may, as appropriate, assess whether response measures are already addressed by their domestic law on civil liability.

8. Response measures shall be implemented in accordance with domestic law.

## Article 6
## EXEMPTIONS

1. Parties may provide, in their domestic law, for the following exemptions:

(a) Act of God or *force majeure*; and

(b) Act of war or civil unrest.

2. Parties may provide, in their domestic law, for any other exemptions or mitigations as they may deem fit.

Article

## 7

## TIME LIMITS

Parties may provide, in their domestic law, for:

(a) Relative and/or absolute time limits including for actions related to response measures; and

(b) The commencement of the period to which a time limit applies.

Article

## 8

## FINANCIAL LIMITS

Parties may provide, in their domestic law, for financial limits for the recovery of costs and expenses related to response measures.

Article

## 9

## RIGHT OF RECOURSE

This Supplementary Protocol shall not limit or restrict any right of recourse or indemnity that an operator may have against any other person.

Article

## 10

## FINANCIAL SECURITY

1. Parties retain the right to provide, in their domestic law, for financial security.

2. Parties shall exercise the right referred to in paragraph 1 above in a manner consistent with their rights and obligations under international law, taking into account the final three preambular paragraphs of the Protocol.

3. The first meeting of the Conference of the Parties serving as the meeting of the Parties to the Protocol after the entry into force of the Supplementary Protocol shall request the Secretariat to undertake a comprehensive study which shall address, *inter alia*:

(a) The modalities of financial security mechanisms;

(b) An assessment of the environmental, economic and social impacts of such mechanisms, in particular on developing countries; and

(c) An identification of the appropriate entities to provide financial security.

Article

# 11

## RESPONSIBILITY OF STATES FOR INTERNATIONALLY WRONGFUL ACTS

This Supplementary Protocol shall not affect the rights and obligations of States under the rules of general international law with respect to the responsibility of States for internationally wrongful acts.

Article

# 12

## IMPLEMENTATION AND RELATION TO CIVIL LIABILITY

1. Parties shall provide, in their domestic law, for rules and procedures that address damage. To implement this obligation, Parties shall provide for response measures in accordance with this Supplementary Protocol and may, as appropriate:

(a) Apply their existing domestic law, including, where applicable, general rules and procedures on civil liability;

(b) Apply or develop civil liability rules and procedures specifically for this purpose; or

(c) Apply or develop a combination of both.

2. Parties shall, with the aim of providing adequate rules and procedures in their domestic law on civil liability for material or personal damage associated with the damage as defined in Article 2, paragraph 2 (b):

(a) Continue to apply their existing general law on civil liability;

(b) Develop and apply or continue to apply civil liability law specifically for that purpose; or

(c) Develop and apply or continue to apply a combination of both.

3. When developing civil liability law as referred to in subparagraphs (b) or (c) of paragraphs 1 or 2 above, Parties shall, as appropriate, address, *inter alia*, the following elements:

(a) Damage;

(b) Standard of liability, including strict or fault-based liability;

(c) Channelling of liability, where appropriate;

(d) Right to bring claims.

## Article 13

## ASSESSMENT AND REVIEW

The Conference of the Parties serving as the meeting of the Parties to the Protocol shall undertake a review of the effectiveness of this Supplementary Protocol five years after its entry into force and every five years thereafter, provided information requiring such a review has been made available by Parties. The review shall be undertaken in the context of the assessment and review of the Protocol as specified in Article 35 of the Protocol, unless otherwise decided by the Parties to this Supplementary Protocol. The first review shall include a review of the effectiveness of Articles 10 and 12.

## Article 14

## CONFERENCE OF THE PARTIES SERVING AS THE MEETING OF THE PARTIES TO THE PROTOCOL

1. Subject to paragraph 2 of Article 32 of the Convention, the Conference of the Parties serving as the meeting of the Parties to the Protocol shall serve as the meeting of the Parties to this Supplementary Protocol.

2. The Conference of the Parties serving as the meeting of the Parties to the Protocol shall keep under regular review the implementation of this Supplementary Protocol and shall make, within its mandate, the decisions necessary to promote its effective implementation. It shall perform the functions assigned to it by this Supplementary Protocol and, *mutatis mutandis*, the functions assigned to it by paragraphs 4 (a) and (f) of Article 29 of the Protocol.

## Article 15

## SECRETARIAT

The Secretariat established by Article 24 of the Convention shall serve as the secretariat to this Supplementary Protocol.

Article

# 16

## RELATIONSHIP WITH THE CONVENTION AND THE PROTOCOL

1. This Supplementary Protocol shall supplement the Protocol and shall neither modify nor amend the Protocol.

2. This Supplementary Protocol shall not affect the rights and obligations of the Parties to this Supplementary Protocol under the Convention and the Protocol.

3. Except as otherwise provided in this Supplementary Protocol, the provisions of the Convention and the Protocol shall apply, *mutatis mutandis*, to this Supplementary Protocol.

4. Without prejudice to paragraph 3 above, this Supplementary Protocol shall not affect the rights and obligations of a Party under international law.

Article

# 17

## SIGNATURE

This Supplementary Protocol shall be open for signature by Parties to the Protocol at the United Nations Headquarters in New York from 7 March 2011 to 6 March 2012.

Article

# 18

## ENTRY INTO FORCE

1. This Supplementary Protocol shall enter into force on the ninetieth day after the date of deposit of the fortieth instrument of ratification, acceptance, approval or accession by States or regional economic integration organizations that are Parties to the Protocol.

2. This Supplementary Protocol shall enter into force for a State or regional economic integration organization that ratifies, accepts or approves it or accedes thereto after the deposit of the fortieth instrument as referred to in paragraph 1 above, on the ninetieth day after the date on which that State or regional economic integration organization deposits its instrument of ratification, acceptance, approval, or accession, or on the date on which the Protocol enters into force for that State or regional economic integration organization, whichever shall be the later.

3. For the purposes of paragraphs 1 and 2 above, any instrument deposited by a regional economic integration organization shall not be counted as additional to those deposited by member States of such organization.

Article

## 19

## RESERVATIONS

No reservations may be made to this Supplementary Protocol.

Article

## 20

## WITHDRAWAL

1. At any time after two years from the date on which this Supplementary Protocol has entered into force for a Party, that Party may withdraw from this Supplementary Protocol by giving written notification to the Depositary.

2. Any such withdrawal shall take place upon expiry of one year after the date of its receipt by the Depositary, or on such later date as may be specified in the notification of the withdrawal.

3. Any Party which withdraws from the Protocol in accordance with Article 39 of the Protocol shall be considered as also having withdrawn from this Supplementary Protocol.

Article

## 21

## AUTHENTIC TEXTS

The original of this Supplementary Protocol, of which the Arabic, Chinese, English, French, Russian and Spanish texts are equally authentic, shall be deposited with the Secretary-General of the United Nations.

IN WITNESS WHEREOF the undersigned, being duly authorized to that effect, have signed this Supplementary Protocol.

DONE at Nagoya on this fifteenth day of October two thousand and ten.



BIO GAS

Printed on Rolland Enviro100 Print, which contains 100% post-consumer fibre, is Environmental Choice, Processed Chlorine Free, and manufactured in Canada by Cascades using biogas energy.

May 2011

ISBN: 92-9225-324-7

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាន់ខ្ពស់ នៃក្របខណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | លោកវរសេនីយ៍ឯក | **លុយ ឈីន** | អត្តលេខ | ០៧៤៣ |
| ២- | លោកវរសេនីយ៍ឯក | **អ៊ុច ទូច** | អត្តលេខ | ១២៤៧៤ |
| ៣- | លោកវរសេនីយ៍ឯក | **សៀន សារ័ត្ន** | អត្តលេខ | ០៥៧០៤ |
| ៤- | លោកវរសេនីយ៍ឯក | **ស៊ិន ណៃទុយ** | អត្តលេខ | ០៧៧៩ |
| ៥- | លោកវរសេនីយ៍ឯក | **ស៊ូ ម៉ារ៉ាឌី** | អត្តលេខ | ០៣១០៥ |
| ៦- | លោកវរសេនីយ៍ឯក | **សំ ធីរៈ** | អត្តលេខ | ០១៤០៩ |

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរស.១៣០៦.៥៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ:៥៧២ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៤១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **នាយ គឹមសុន** អត្តលេខ ០៥០២ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៩. ១៣០៦. ៥៤៩

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៥៧០ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការគណៈរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោក **សុខវណ្ណា ពិសាខា** អត្តលេខ ១២៥៦៥ នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពនល.១៣០៦.៥៨៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

លេខៈ ៥៧៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រីរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូនលោកវរសេនីយ៍ឯក **អ៊ិន សាខុធ** អត្តលេខ ៣៧១៩៧ នាយនគរបាលជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរល.១៣០៦.៥៩០

*ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣*

លេខ: ៥៦៩ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **រីសេ ដឺនីស** (DENIS RICHER) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៤៩ នៅសារ៉ង់តុង ឡឺប៉ុង (Charenton-Le Pont) សាធារណរដ្ឋបារាំង។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៥៥១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
**រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣**
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

[illegible] ១៣០៦-៥៩១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **វ៉េន ម៉ៃខល វេចមេន** (WAYNE MICHAEL WEIGHTMAN) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៦១ នៅភូមិអ៊ីហ្គល រដ្ឋផេនស៊ីលវេននីញ៉ា សហរដ្ឋអាមេរិក ដោយប្តូរឈ្មោះជា **គីម តារា** (KIM DARA)។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣០៦.៥៩២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៥៥៧ ស.ណ
**សំណៅចម្លងមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ប្រេដលីយ ហ្គីល ហ្គែនណឺ** (BRADLEY GILES GARNER) ជនជាតិអាមេរិក សញ្ជាតិអាមេរិក កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ នៅទីក្រុងអូហ្គូស្តា រដ្ឋចចារ សហរដ្ឋអាមេរិក។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាស. ១៣០៦.៥៩៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣

លេខ: ៥៥៣ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

**ចំពោះ**

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក សរុបចំនួន ២៣រូប បានលះបង់កម្លាំងកាយ ចិត្ត និង បរិច្ចាគធនធានផ្ទាល់ខ្លួនរួមចំណែកកសាងអគារសាកលវិទ្យាល័យ **ជា ស៊ីម កំចាយមារ** ខេត្តព្រៃវែង

**នូវ**

**ក-** **គ្រឿងឥស្សរិយយស ជាតូបការ :**

១-លោកជំទាវ **ញៀម សាខន ស ខេង**
២-ឯកឧត្តម **ម៉ម សុផាណា**
៣-ឯកឧត្តម **អ៊ុយ ស៊ីម**
៤-ឯកឧត្តម **អ៊ុក គីមលេខ**
៥-ឯកឧត្តម **ឆាំ សុជាតិវឌ្ឍ**
៦-លោកជំទាវ **ឆន់ ខុន យឹម ឆៃលី**
៧-លោកជំទាវ **ម៉ៅ ម៉ាល័យ កែ គីមយ៉ាន**
៨-លោកជំទាវ **អ៊ីន សុវណ្ណរិទ្ធ ឆាំ សុជាតិវឌ្ឍ**
៩-ឯកឧត្តម **ឆោ ស៊ុនលី**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឧត្តមសេនីយ៍ទោ **គួច ឆេងទេង**
២-ឧត្តមសេនីយ៍ត្រី **ស សុខា**
៣-វរសេនីយ៍ឯក **កែ សួនសុភាព**

**គ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តមឧកញ៉ា **គី ឌីគា**
២-ឯកឧត្តម **ហុក ជា**
៣- លោកជំទាវ **ឃុន ហៀង ភាំង ម៉េងហ៊ុយ**

**ឃ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-លោក **គៅ ហ៊ួ (Jimmy)**
២-លោកស្រី **កែ សួនសុភី**
៣-លោកជំទាវ **លី សុខខេង គី ឌីគា**
៤-លោកជំទាវ **ហេង ណាយ ហុក ជា**
៥- **Mr. BUDIARSA SASTRAWINATA**
៦- **Mr. AGUSSURJA WIDJAJA**

**ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

ឧត្តមសេនីយ៍ទោ **ឌុច សារឿន**

**ច-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

លោក **ភាំង ឡេង**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចរណ. ១៣០៦.៥៩៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣*

លេខៈ ៥៧០ ស.ណ
**សំណៅដែលមានតម្លៃដូចការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋាភិបាល**

**ស៊ិយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៤៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

**ចំពោះ**

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សរុបចំនួន ៥១រូប ដែលបានឧបត្ថម្ភថវិកា ផ្ទាល់ខ្លួនជាច្រើន រួមចំណែកកសាងអគារសាកលវិទ្យាល័យ **ជា ស៊ីម** កំចាយមារ សំដៅលើកកម្ពស់ វិស័យអប់រំសិក្សាធិការមានការរីកចម្រើនជាលំដាប់

**នូវ**

**ក-គ្រឿងឥស្សរិយយស ជាតូបការ :**

១-ឯកឧត្តម **ស ថេង**
២-លោកជំទាវ **ហ៊ុន គីមឡេង នេត សាវឿន**
៣- លោកជំទាវ **ឡុង សាខន ស៊ិន សុង**
៤-ឯកឧត្តម **គង់ វិបុល**
៥-ឯកឧត្តម **ម៉ិន លើត**
៦-ឯកឧត្តម **ថ្វាង សុផាន់**
៧-ឯកឧត្តម **ស៊ាង ម៉ិនលាង**
៨-ឧកញ៉ា **សុខ ហុង**
៩-ឯកឧត្តម **តាក វណ្ណថា**

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **ខាត់ សុខា**
២-ឯកឧត្តម **សំ ផន**
៣-ឯកឧត្តម **រស់ សារិទ្ធ**
៤-ឯកឧត្តម **សូខន ឫទ្ធិគុណ**
៥-ឯកឧត្តម **ពេជ្រ សុធិរា**
៦-វរសេនីយ៍ឯក **ស រដ្ឋា** អត្តលេខ ៥៤៨៥៧

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :**

១-លោក **ទ៉ែត តារា**
២-លោក **ហៀង វីរិយា**
៣-លោក **វង្ស សុវណ្ណា**
៤-លោកស្រី **ខៃ គីមសេរី**

**ឃ-គ្រឿងឥស្សរិយយស សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិ មុនីវង្ស កុសុមៈនារីរ័ត្ន ថ្នាក់ មហាសេរីវឌ្ឍន៍ :**

១-ឯកឧត្តម **ម៉ៅ ម៉ិនណារិន**
២-ឯកឧត្តម **ជា សុគន្ធា**
៣-ឯកឧត្តម **ជា សុមេធី**
៤-ឯកឧត្តម **អ៊ុច សុខុន**
៥-លោក **ស ថេន**

**ង-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

ឯកឧត្តម **អ៊ាម អេងហុង**

**ច-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :**

លោកជំទាវ **ម៉ៅ សុគន្ធា គុយ ម៉ិនសន**

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឆ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម TRAN QUOC LIEM
២-ឯកឧត្តម ចៅ គៀង
៣-លោកជំទាវ សួង ស្រីនួច
៤-លោក ម៉ៅ ធនិន
៥-លោក ផាន់ ចាន់ធុល
៦-លោក តុង សេង
៧-លោកជំទាវ គូ គីមឡុង
៨-លោកជំទាវ ជីវ ឡេង
៩-លោកជំទាវ ឈាង សារាន ឡុយ សុផាត
១០-លោកជំទាវ សាយ សុខា ហ៊ុំ ផុំវី
១១-លោកជំទាវ ស សៀន ឈុន ឈង់
១២-លោកជំទាវ ពៅ សារុម ឡូរ៉ុំ សុខា
១៣-លោកជំទាវ នូ ឈាន ចាន់អ៊ាន
១៤-លោកស្រី ថៃ គីមសេរី
១៥-លោក សួ សារិទ្ធ
១៦-លោក ទ៊ឹក ចំរើន

ជ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា :

១-លោកស្រី ហ៊ូ រី ទ៊ឹក ជូរ
២-លោក ហួយ ឈុនហ៊ុយ
៣-លោក ម៉ិន មណីរដ្ឋ
៤-លោក ទ៊ឹក ចាន់ណារ៉ា
៥-លោកស្រី ទ៊ឹក ផាន់ណា
៦-លោកស្រី ទ៊ឹក ផាន់នី
៧-លោក ទ៊ឹក សុផល
៨-លោក តាយ ចំនួតារា
៩-លោក អ៊ុំ ចំរើន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៦១៣.៥៩៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៥៦១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល
សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៨៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០៣រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ បានខិតខំបូជា យកអស់កម្លាំងកាយប្រាជ្ញា ស្មារតី និងធនធានផ្ទាល់ខ្លួន ក្នុងកិច្ចកសាងសមិទ្ធផលនានា ស្ថិតក្នុងខេត្តព្រៃវែង នាពេលកន្លងមក

នូវ

ក. គ្រឿងឥស្សរិយយស ជាតូបការ

១- ឧកញ៉ា អាន ម៉ាឌី

២- ឧកញ៉ា ញឹម សុខាល័យ

ខ. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

- ឧកញ៉ា លឹម ប៊ុណ្ណា

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស. ១៣០៦. ៥៩៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៥៥៥ ស.ណ
**សំណៅចម្លងដែលមានសេចក្តីដូចការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

ចំពោះ

សប្បុរសជន ចំនួន ០២រូប បានចំណាយថវិកា ជួយកសាងសមិទ្ធផលនានា នៅកងពលតូចលេខ ៧០ និងសមិទ្ធផលជាច្រើន ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រេចបានលទ្ធផលល្អប្រសើរ

នូវ

គ្រឿងឥស្សរិយយស **ជាតួបការ**

១- ឧកញ៉ា ស្រី ខួន

២- ឧកញ៉ា ស្រី ខុទ្ធី

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពនស. ១៣០៦.៥៩៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៥៦៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៦

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

លោក សរ ខុន្តា

ដែលបានបរិច្ចាគកម្លាំងកាយ ចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន
ចូលរួមជួយអភិវឌ្ឍន៍មូលដ្ឋាន នៅឃុំចោងម៉ោង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ទទួលបានលទ្ធផលល្អប្រសើរ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរស.១៣០៦.៥៩៤

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០១៣*

លេខៈ ៥៨០ ស.ណ
**សំណៅដែលមានតម្លៃស្មើជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩២

## យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ក្រុមប្រឹក្សាភិបាលអាណត្តិទី៤ មន្ត្រីត្រួតពិនិត្យរដ្ឋ អមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនិងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ចំនួន០៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចនិងដឹកនាំគ្រប់គ្រងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញព្រមទាំងសម្រេចបានលទ្ធផលល្អលើការសាងសង់រោងចក្រផលិតទឹកស្អាតនិរោធជំហានទី១

នូវ

**ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ជូ | ទិជិត្ត | ៣-ឯកឧត្តម | ឯក | សុនចាន់ |
| ២-ឯកឧត្តម | អ៊ឹម | ខេង | ៤-ឯកឧត្តម | នេត | មុន្នី |

**ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា**

| | | | | | |
|---|---|---|---|---|---|
| ១-ឯកឧត្តម | ម៉េង | សក្តិធារ៉ា | ៤-លោក | នួន | សុមេធ |
| ២-លោក | ស៊ឹម | ស៊ីថា | ៥-លោក | ឡុង | ណារ៉ូ |
| ៣-ឯកឧត្តម | សុខ | ហេង | | | |

**ព្រះហស្ដលេខា និងព្រះរាជលញ្ឆករ**
**នរោត្ដម សីហមុនី**

ចបល. ១៣០៦.៥៩៩

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ: ៥៩១ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០១៣
អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**ចំពោះ**

សប្បុរសជន ចំនួន០៣រូប មានគុណបំណាច់និងស្នាដៃល្អក្នុងការចូលរួមកសាងស្ថាបនាជាតិ
សម្រេចបានលទ្ធផលល្អប្រសើរ

**នូវ**

**ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍**
ឯកឧត្តម ឡា ឡៃ

**ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**
វរសេនីយ៍ឯក កែន វណ្ណៈ

**គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**
លោក កេត ម៉ៅ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤.១៣០៦.៦០០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣

លេខ ៥៩២ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៥៩៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

**គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍**

**ចំពោះ**

លោកស្រី Le Nu Thuy Duong

អគ្គនាយករងក្រុមហ៊ុនវាយកូនគោល ឡុងថាញ់ ដែលមានគុណបំណាច់ និងស្នាដៃល្អក្នុងការចូលរួម ជួយសាងសង់អាគារសិក្សាថ្មី នៅវិទ្យាល័យស្ទឹងត្រង់ ខេត្តកំពង់ចាម និងបានឧបត្ថម្ភថវិកា បន្ថែមទៀតសំរាប់បំពាក់កុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីនហ្វូតូកូពី ព្រមទាំងបានជួយឧបត្ថម្ភ ក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកធ្វើការវះកាត់ភ្នែក ជូនប្រជាពលរដ្ឋនៅតាមខេត្តមួយចំនួន

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ពាសស. ១៣០៦.៦០១*

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១៣*

លេខ: ៥៧៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៣
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..២៨៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១ នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស
- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក** ( HI-PARK SEZ ) ដែលមានទីតាំងស្ថិតនៅភូមិថ្នល់ជាតិ សង្កាត់ច្រកម្ទេស ក្រុងបាវិត ខេត្តស្វាយរៀង ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក** មានទំហំ ២៦៣,១៣ ហិកតា (ពីររយហុកសិបបីហិកតា និងដប់បីអា) ដូចមានប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក** ដូចមានកំណត់ក្នុងមាត្រា ២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃ **តំបន់សេដ្ឋកិច្ចពិសេស ហាយ-ផាក** នេះ នឹងស្ថិតក្រោមវិសាលភាព នៃច្បាប់ និងបទប្បញ្ញត្តិនានា នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តស្វាយរៀង និងក្រុមហ៊ុន ហាយ-ផាក អេសអ៊ីហ្សេត ឌីវេឡុបមេន ខូ អិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ខែ ឧសភា ឆ្នាំ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

ដើម្បីសុំចុះហត្ថលេខា

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

**សុខ ចិន្តា សោភា**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៥.៦.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## បែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញក្រឹត្យលេខ៥៦ក្រ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ.
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងជានាការអនុវត្តសិទ្ធិទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទនិងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសជាបុរសឬជាស្ត្រីដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរហើយមានបំណងទាមទារសញ្ជាតិខ្មែរ។

## ជំពូកទី២

## បែបបទនៃការទាមទារសញ្ជាតិខ្មែរ

**មាត្រា ៤.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលមានបំណងទាមទារសញ្ជាតិខ្មែរ ត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃ។

**មាត្រា ៥.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលទាមទារសញ្ជាតិខ្មែរ ត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំនិងត្រូវបំពេញបែបបទដូចខាងក្រោម៖

- ពាក្យសុំទាមទារសញ្ជាតិខ្មែរចំនួន០២(ពីរ)ច្បាប់
- លិខិតបញ្ជាក់ឯកភាពរបស់សហព័ទ្ធជាពលរដ្ឋខ្មែរចំនួន០២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនមានស្នាមម្រាមដៃ ឈ្មោះ មានបិទរូបថតទំហំ ៤ស.ម.គុណ៦ស.ម.ចំនួន ០២(ពីរ)ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០(ដប់)សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- លិខិតបញ្ជាក់ទីលំនៅនិងលិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំឬចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន០១(មួយ)ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន០១ (មួយ) ច្បាប់ ដោយមានបញ្ជាក់ពីស្ថានទូតឬស្ថានតំណាងរបស់ខ្លួន
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន០២(ពីរ)ច្បាប់
- លិខិតឆ្លងដែនថតចម្លងរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន០២(ពីរ)ច្បាប់។

**មាត្រា ៦.-**

ការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីត្រូវបង់កម្រៃសេវារដ្ឋបាល។

កម្រៃសេវារដ្ឋបាលនៃការទាមទារសញ្ជាតិខ្មែរនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## នីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ

**មាត្រា ៧.-**

នីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំឯកសារសុំទាមទារសញ្ជាតិខ្មែរនិងនីតិវិធីប្តឹងជំទាស់របស់សហព័ទ្ធជាពលរដ្ឋខ្មែរចំពោះការទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៩.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវប្រគល់ជូនសាមីខ្លួនបន្ទាប់ពីបានធ្វើសម្បថរួច ដោយក្រសួងមហាផ្ទៃ។

ខ្លឹមសារនៃសម្បថមានអត្ថន័យដូចតទៅ៖

« ខ្ញុំសូមសច្ចាជាឱឡារិកថាខ្ញុំមានភក្តីភាពនិងសេចក្តីស្នេហាចំពោះជាតិមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងក្នុងពេលបច្ចុប្បន្នទាំងក្នុងពេលអនាគត »។

« ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការការពារខឿនឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្នទាំងក្នុងពេលអនាគត »។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ២៨៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទនិងនីតិវិធីនៃការសុំសញ្ជាតូបនីយកម្ម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាការអនុវត្តរាល់ការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រី ដោយសញ្ជាតូបនីយកម្ម។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីបែបបទនិងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរស ឬជាស្ត្រីដោយសញ្ជាតូបនីយកម្ម។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជនបរទេសជាបុរសឬជាស្ត្រីដែលសុំចូលសញ្ជាតិខ្មែរដោយ សញ្ជាតូបនីយកម្ម។

## ជំពូកទី២

## បែបបទនៃការសុំសញ្ជាតូបនីយកម្ម

**មាត្រា ៤.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលមានបំណងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវបំពេញ លក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៤នៃច្បាប់ស្តីពីសញ្ជាតិ។

**មាត្រា ៥.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវមានវត្តមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជានៅពេលដាក់ពាក្យសុំនិងត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃដូចខាងក្រោម៖

- ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន០២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានស្នាមម្រាមដៃ ឈ្មោះ មានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម.ចំនួន ០២(ពីរ)ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០(ដប់)សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- សេចក្តីចម្លងសំបុត្រកំណើត ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ជនបរទេសចំនួន០២(ពីរ)ច្បាប់
- លិខិតឆ្លងដែនថតចម្លងនិងទិដ្ឋាការថតចម្លងរបស់សាមីខ្លួនដែលនៅមានសុពលភាពចាប់ពីថ្ងៃចូលដំបូង រហូតដល់ថ្ងៃចូលចុងក្រោយក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន០២(ពីរ)ច្បាប់
- លិខិតបញ្ជាក់ទីលំនៅនិងលិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំឬចៅសង្កាត់០១(មួយ)ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពចេញដោយក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា០១(មួយ)ច្បាប់

- លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស០១(មួយ)ច្បាប់ដោយមានបញ្ជាក់ពីស្ថានទូតឬស្ថានតំណាងរបស់ខ្លួន
- ខិតបញ្ជាក់សុខភាពនិងកាយសម្បទាចេញដោយសមត្ថកិច្ចសុខាភិបាលចំនួន០២(ពីរ)ច្បាប់
- ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ចេញដោយការិយាល័យអន្តោប្រវេសន៍នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ០១(មួយ)ច្បាប់ លើកលែងតែជនបរទេសដែលបានកំណត់សិទ្ធិដូចមានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ និងមាត្រា១៣នៃច្បាប់ស្តីពីសញ្ជាតិ។

**មាត្រា ៦.-**

ការសុំចូលសញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ជាតូបនីយកម្ម ត្រូវបង់កម្រៃសេវារដ្ឋបាល។

កម្រៃសេវារដ្ឋបាលនៃការសុំចូលសញ្ជាតិខ្មែរនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## នីតិវិធីនៃការសុំសញ្ជាតូបនីយកម្ម

**មាត្រា ៧.-**

នីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំឯកសារសុំចូលសញ្ជាតិខ្មែរ និងការប្រឡងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មរបស់ជនបរទេសជាបុរសឬជាស្ត្រី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៨.-**

ការផ្តល់សញ្ជាតិខ្មែររបស់ជនបរទេសជាបុរសឬជាស្ត្រីដោយសញ្ជាតូបនីយកម្ម ត្រូវសម្រេចដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៩.-**

ជនបរទេសជាបុរសឬជាស្ត្រីដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។

ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរ ត្រូវប្រគល់ជូនសាមីខ្លួនបន្ទាប់ពីបានធ្វើសម្បថរួច ដោយក្រសួងមហាផ្ទៃ។

ខ្លឹមសារនៃសម្បថមានអត្ថន័យដូចតទៅ៖

« ខ្ញុំសូមសច្ចាជាឱឡារិកថាខ្ញុំមានភក្តីភាពនិងសេចក្តីស្នេហាចំពោះជាតិមាតុភូមិកម្ពុជារបស់ខ្ញុំ ហើយប្តេជ្ញាធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីការពារនិងគោរពរដ្ឋធម្មនុញ្ញនិងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាទាំងក្នុងពេលបច្ចុប្បន្នទាំងក្នុងពេលអនាគត »។

« ខ្ញុំសូមប្តេជ្ញាជាឱឡារិកថានឹងតាំងខ្លួនជាពលរដ្ឋខ្មែរដ៏ល្អ ហើយហ៊ានលះបង់គ្រប់បែបយ៉ាងដើម្បីចូលរួមចំណែកក្នុងការការពារឋឿនឯករាជ្យជាតិ អធិបតេយ្យជាតិ បូរណភាពទឹកដី សន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ព្រមទាំងលើកកម្ពស់កិត្យានុភាព នៃព្រះរាជាណាចក្រកម្ពុជា ទាំងក្នុងពេលបច្ចុប្បន្ន ទាំងក្នុងពេលអនាគត »។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- តុលាការកំពូលនិងមហាអយ្យការអមតុលាការកំពូល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៤៨៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## នីតិវិធីនិងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធានាការអនុវត្តសិទ្ធិក្នុងការសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីតាមភាពចាំបាច់និងតម្រូវការជាក់ស្តែងរបស់សាមីខ្លួនដោយស្ម័គ្រចិត្តនិងគ្មានការបង្ខិតបង្ខំ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនីតិវិធីនិងលក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរជាបុរសឬជាស្ត្រី។

**មាត្រា ៣._**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីដែលមានបំណងសុំលះបង់សញ្ជាតិខ្មែរ។

## ជំពូកទី២
## នីតិវិធីនៃការសុំលះបង់សញ្ជាតិខ្មែរ

**មាត្រា ៤._**

ពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីដែលមានបំណងសុំលះបង់សញ្ជាតិខ្មែរត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃ។

នីតិវិធីនៃការទទួលនិងការពិនិត្យលើសំណុំឯកសារសុំលះបង់សញ្ជាតិខ្មែរ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៥._**

ការសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៦._**

ការសុំលះបង់សញ្ជាតិរបស់ពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីត្រូវបង់កម្រៃសេវារដ្ឋបាល។

កម្រៃសេវារដ្ឋបាលនៃការសុំលះបង់សញ្ជាតិខ្មែរនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៣
## លក្ខខណ្ឌនៃការសុំលះបង់សញ្ជាតិខ្មែរ

**មាត្រា ៧._**

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ១៨(ដប់ប្រាំបី)ឆ្នាំយ៉ាងតិចអាចសុំលះបង់សញ្ជាតិខ្មែរបានក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានការបង្ខិតបង្ខំ។

**មាត្រា ៨._**

សាមីជនដែលសុំលះបង់សញ្ជាតិខ្មែរ ត្រូវដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ និងត្រូវបំពេញបែបបទដូចខាងក្រោម៖

- ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន០២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួន មានស្នាមម្រាមដៃ ឈ្មោះ មានបិទរូបថតទំហំ៤ស.ម.គុណ៦ស.ម ចំនួន០២(ពីរ)ច្បាប់ និងមានភ្ជាប់រូបថតចំនួន១០(ដប់)សន្លឹក។ រូបថតទាំងអស់ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតា
- សៀវភៅគ្រួសារថតចម្លងឬសៀវភៅស្នាក់នៅថតចម្លង០១(មួយ)ច្បាប់
- សេចក្តីចម្លងសំបុត្រកំណើតឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លងឬលិខិតឆ្លងដែនថតចម្លង០១(មួយ)ច្បាប់
- លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀតឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិ០១(មួយ)ច្បាប់

- ចំពោះពលរដ្ឋខ្មែរជាបុរសឬជាស្ត្រីរស់នៅបរទេសស្របច្បាប់ត្រូវមានលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួន នៃប្រទេសនោះ០១(មួយ)ច្បាប់។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា ៩._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ១០._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី-ខេត្ត
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការគ្រប់គ្រងសន្តិសុខឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងលើកទឹកចិត្តក្នុងការបង្កើតនិងការពង្រឹងសន្តិសុខឯកជនដើម្បីចូលរួមចំណែកក្នុងការថែរក្សាការពារទ្រព្យសម្បត្តិ អាយុជីវិតប្រជាជននិងការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីការបង្កើត ការគ្រប់គ្រង និងសកម្មភាពរបស់សន្តិសុខឯកជនគ្រប់ប្រភេទ។

**មាត្រា ៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសន្តិសុខឯកជនគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៤.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **សន្តិសុខឯកជន** សំដៅដល់សន្តិសុខដែលបង្កើតឡើងដោយសហគ្រាសគ្រឹះស្ថាននានា។ សន្តិសុខឯកជនមានពីរប្រភេទគឺសន្តិសុខឯកជនដែលបង្កើតឡើងដោយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងសន្តិសុខឯកជនដែលបង្កើតឡើងដោយសហគ្រាសគ្រឹះស្ថាននានា ។
- **ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន** សំដៅដល់នីតិបុគ្គលដែលបានបង្កើតភ្នាក់ងារសន្តិសុខឯកជនដើម្បីផ្តល់សេវាសន្តិសុខដល់អតិថិជនដោយគិតថ្លៃឈ្នួល ។
- **សហគ្រាសគ្រឹះស្ថាននានា** សំដៅដល់ក្រុមហ៊ុននានាដែលមិនផ្តល់សេវាសន្តិសុខឯកជន គ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន អង្គការមិនមែនរដ្ឋាភិបាលនានាដែលបង្កើតភ្នាក់ងារសន្តិសុខឯកជន ដើម្បីបម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន ។
- **ភ្នាក់ងារសន្តិសុខឯកជន** សំដៅដល់រូបវន្តបុគ្គលដែលត្រូវបានជ្រើសរើសដោយក្រុមហ៊ុន ឬសហគ្រាសគ្រឹះស្ថាននានាដើម្បីបម្រើការងារសន្តិសុខ ។
- **សេវាសន្តិសុខឯកជន** សំដៅដល់ការផ្តល់សេវាថែរក្សាការពារទ្រព្យសម្បត្តិ អាយុជីវិត និងការផ្តល់សេវាកម្មផ្សេងៗទៀតតាមការព្រមព្រៀង ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា ៥.-**

ក្រសួងមហាផ្ទៃដោយមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ មានសមត្ថកិច្ចក្នុងការផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ៦.-**

អគ្គស្នងការដ្ឋាននគរបាលជាតិ មានភារកិច្ចលើកសំណើជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃពិនិត្យនិងសម្រេចលើកិច្ចការដូចខាងក្រោម ៖

- ផ្តល់ការហ្វឹកហ្វឺនបណ្តុះបណ្តាលជំនាញឯកទេសនិងច្បាប់ចាំបាច់នានាជាធរមានដល់ភ្នាក់ងារសន្តិសុខរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងរបស់សហគ្រាសគ្រឹះស្ថាននានា
- អនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនប្រើសម្ភារៈ មធ្យោបាយ បច្ចេកទេស សត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- ចាត់មន្ត្រីនគរបាលជំនាញចុះសហការជាមួយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន
- ព្រមាន ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្មរបស់ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលធ្វើសកម្មភាពល្មើសច្បាប់។

**មាត្រា ៧.-**

រដ្ឋបាលរាជធានី ខេត្ត ដោយមានស្នងការដ្ឋាននគរបាលរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចក្នុងការផ្តល់ការអនុញ្ញាតឱ្យសហគ្រាសគ្រឹះស្ថាននានាបង្កើតភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន។

**មាត្រា ៨.-**

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានភារកិច្ចលើកសំណើជូនអភិបាលនៃគណៈអភិបាលរាជធានីខេត្តពិនិត្យនិងសម្រេចលើកិច្ចការដូចខាងក្រោម ៖

- អនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនរបស់សហគ្រាសគ្រឹះស្ថាននានាប្រើសម្ភារៈ មធ្យោបាយ បច្ចេកទេសសត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- ចាត់មន្ត្រីនគរបាលជំនាញចុះសហការជាមួយសហគ្រាសគ្រឹះស្ថាននានា
- ព្រមាន ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតបង្កើតភ្នាក់ងារសន្តិសុខរបស់សហគ្រាសគ្រឹះស្ថាននានាដែលធ្វើសកម្មភាពល្មើសច្បាប់។

## ជំពូកទី៣
## ការអនុញ្ញាតផ្តល់សេវាសន្តិសុខឯកជន
## និងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន

**មាត្រា ៩.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតប្រកបអាជីវកម្មនៅក្រសួងមហាផ្ទៃ ។

ចំពោះសហគ្រាសគ្រឹះស្ថាននានា ដែលជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារក្នុងសហគ្រាសគ្រឹះស្ថានរបស់ខ្លួន ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតនៅរដ្ឋបាលរាជធានី ខេត្តដែលសាមីសហគ្រាសគ្រឹះស្ថាននោះតាំងនៅ ។

**មាត្រា ១០.-**

លក្ខខណ្ឌនិងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជននិងនិងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ១១.-**

រាល់ការស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មផ្តល់សេវាកម្មសន្តិសុខឯកជន និងការអនុញ្ញាតជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនសម្រាប់បម្រើការងារនៅតាមសហគ្រាសគ្រឹះស្ថាននានា ត្រូវបង់កម្រៃសេវារដ្ឋបាលនៃការអនុញ្ញាតនិងកម្រៃសេវារដ្ឋបាលនៃកិច្ចសហការជាមួយសមត្ថកិច្ចនគរបាលជាតិ។

កម្រៃសេវារដ្ឋបាលនៃការអនុញ្ញាតនិងកម្រៃសេវារដ្ឋបាលនៃកិច្ចសហការជាមួយសមត្ថកិច្ចនគរបាលជាតិត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

# ជំពូកទី៤
# ភារកិច្ចរបស់ក្រុមហ៊ុនផ្ដល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាននានា

**មាត្រា ១២.-**

ក្រុមហ៊ុនផ្ដល់សេវាសន្តិសុខឯកជនមានភារកិច្ចដូចខាងក្រោម៖

- សុំការអនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនប្រើឧបករណ៍ សម្ភារៈ បច្ចេកទេស មធ្យោបាយ ឬសត្វសម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- គោរពតាមការកំណត់របស់អគ្គស្នងការដ្ឋាននគរបាលជាតិអំពីជំនាញសន្តិសុខ
- រៀបចំផែនការរួមអំពីសកម្មភាពការពារសន្តិសុខសណ្ដាប់ធ្នាប់របៀបរៀបរយសម្រាប់បម្រើអតិថិជន
- រៀបចំផែនការការពារទីតាំង ទ្រព្យសម្បត្តិ និងអាយុជីវិតរបស់អតិថិជន តាមករណីជាក់ស្ដែងនីមួយៗ
- សុំការអនុញ្ញាតដើម្បីបណ្ដុះបណ្ដាលភ្នាក់ងារសន្តិសុខឯកជនពីអគ្គស្នងការដ្ឋាននគរបាលជាតិ
- ផ្ដល់របាយការណ៍ប្រចាំខែអំពីសកម្មភាពរបស់ក្រុមហ៊ុនផ្ដល់សេវាសន្តិសុខឯកជនជូនអគ្គស្នងការដ្ឋាននគរបាលជាតិ
- សុំកិច្ចអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីចាំបាច់
- ត្រូវធានារ៉ាប់រងលើរបបសន្តិសុខសង្គមដល់ភ្នាក់ងារសន្តិសុខឯកជនតាមច្បាប់ជាធរមាន
- អនុវត្តការផ្ដល់សេវាសន្តិសុខឯកជនស្របតាមច្បាប់ជាធរមាន
- សហការផ្ដល់ភ្នាក់ងារសន្តិសុខតាមសំណើរបស់អគ្គស្នងការដ្ឋាននគរបាលជាតិក្នុងករណីចាំបាច់។

**មាត្រា ១៣.-**

សហគ្រាសគ្រឹះស្ថាននានាមានភារកិច្ចដូចខាងក្រោម៖

- សុំការអនុញ្ញាតឱ្យភ្នាក់ងារសន្តិសុខឯកជនប្រើឧបករណ៍ សម្ភារៈ បច្ចេកទេស មធ្យោបាយ ឬសត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ
- គោរពតាមការកំណត់របស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- រៀបចំផែនការការពារទីតាំង ទ្រព្យសម្បត្តិ និងអាយុជីវិត
- សុំការអនុញ្ញាតដើម្បីបណ្ដុះបណ្ដាលភ្នាក់ងារសន្តិសុខឯកជនតាមរយៈស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- ផ្ដល់របាយការណ៍ប្រចាំខែអំពីសកម្មភាពរបស់ភ្នាក់ងារសន្តិសុខឯកជនជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត
- សុំកិច្ចសហការពីអាជ្ញាធរមានសមត្ថកិច្ចក្នុងករណីចាំបាច់
- ត្រូវធានារ៉ាប់រងលើរបបសន្តិសុខសង្គមដល់ភ្នាក់ងារសន្តិសុខឯកជនតាមច្បាប់ជាធរមាន។

**មាត្រា ១៤.-**

ក្រុមហ៊ុនផ្ដល់សេវាសន្តិសុខឯកជន និងសហគ្រាសគ្រឹះស្ថាននានា ត្រូវផ្ដល់អាទិភាពក្នុងការជ្រើសរើសអតីតមន្ត្រីនគរបាលជាតិ មន្ត្រីកងយោធពលខេមរភូមិន្ទ និងមន្ត្រីរាជការផ្សេងទៀតដែលចូលនិវត្តន៍ ហើយនៅមានកាយសម្បទាល្អអាចធ្វើការងារបាននិងមានប្រវត្តិរូបល្អឲ្យចូលបម្រើការជាភ្នាក់ងារសន្តិសុខរបស់ខ្លួន។

**មាត្រា ១៥.-**

ទីតាំងឬសហគ្រាសគ្រឹះស្ថាននានាដែលមានអ្នកចាំយាម តែមិនមានប្រើឧបករណ៍ សម្ភារៈ ដូចមានចែងក្នុងមាត្រា១២និងមាត្រា១៣នៃអនុក្រឹត្យនេះ ពុំចាំបាច់ស្នើសុំការអនុញ្ញាតទេ តែត្រូវជូនដំណឹងអំពីសមាសភាពនៃអ្នកចាំយាមមកប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដែលមានទីតាំងឬសហគ្រាសគ្រឹះស្ថាននោះតាំងនៅ ។

**មាត្រា ១៦.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនឬសហគ្រាសគ្រឹះស្ថាននានាដែលទទួលបានការអនុញ្ញាតឱ្យធ្វើការងារសន្តិសុខឯកជនគ្មានសិទ្ធិដូចខាងក្រោម៖

- ប្រើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ
- ជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនជាមន្ត្រីរាជការស៊ីវិលឬកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមិនទាន់ចូលនិវត្តន៍
- ប្រើឯកសណ្ឋាន សញ្ញាស័ក្តិដូចឬស្រដៀងនឹងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទនិងរបស់ក្រសួង ស្ថាប័ននានារបស់រដ្ឋ ។

## ជំពូកទី៥
## ទណ្ឌកម្ម

**មាត្រា ១៧.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនឬសហគ្រាសគ្រឹះស្ថាននានា ដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ផ្អាកសកម្មភាពជាបណ្តោះអាសន្ន
- ដកហូតលិខិតអនុញ្ញាតជាស្ថាពរ ។

**មាត្រា ១៨.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនដែលផ្តល់សេវាសន្តិសុខដោយគ្មានការអនុញ្ញាតិ ក្រសួងមហាផ្ទៃត្រូវបញ្ឈប់សកម្មភាពនោះជាបន្ទាន់ និងពិន័យអន្តរការណ៍ជាប្រាក់ ២០.០០០.០០០ (ម្ភៃលាន)រៀល ។

សហគ្រាសគ្រឹះស្ថាននានាដែលជ្រើសរើសសន្តិសុខឯកជនដោយគ្មានការអនុញ្ញាត រដ្ឋបាលរាជធានី ខេត្ត ត្រូវបញ្ឈប់សកម្មភាពនោះជាបន្ទាន់ និងពិន័យអន្តរការណ៍ជាប្រាក់ ១០.០០០.០០០ (ដប់លាន)រៀល ។

ក្នុងករណីនេះ ក្រសួងមហាផ្ទៃ ឬរដ្ឋបាលរាជធានី ខេត្តអាចកសាងសំណុំរឿងបញ្ជូនទៅតុលាការផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា ១៩.-**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជននិងសហគ្រាសគ្រឹះស្ថាននានា ដែលបានទទួលការអនុញ្ញាតឱ្យផ្តល់សេវាសន្តិសុខឯកជន ឬជ្រើសរើសភ្នាក់ងារសន្តិសុខឯកជនមុនពេលអនុក្រឹត្យនេះចូលជាធរមាននៅតែមានសិទ្ធិធ្វើសកម្មភាពបន្តទៀត ប៉ុន្តែត្រូវមកបំពេញតាមលក្ខខណ្ឌ និងបែបបទបន្ថែមក្នុងរយៈពេលយ៉ាងយូរ ០៦(ប្រាំមួយ)ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា ២០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ២១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃ ៣១ ខែ ឧសភា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្ដីគោរពជូន**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២១
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣៧៨...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជន ចំនួន ៣៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងព្រះវិហារ នៅ**វត្តសាគរខ្មៅ** ស្ថិតនៅក្នុងឃុំខ្ញោ ស្រុកកងមាស ខេត្តកំពង់ចាម ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | **សុខ** | **ម៉េងឆា** | គង់នៅខេត្តកំពង់ចាម | បច្ច័យចំនួន ១២.០០០ ដុល្លារ |
| ២-លោកស្រី | **ឡៅ** | **ជុនអេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១៣.០០០ ដុល្លារ |
| ៣-លោក | **ចេង** | **គុកម៉េង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៤-កញ្ញា | **ម៉ៅ** | **មាល្លិះ** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៥-លោក | **គីម** | **គីរ៉ា** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០០០ ដុល្លារ |
| ៦-ឧបាសក | **តាំ** | **គិជ** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៧-ឧបាសក | **ម៉ូ** | **សុខហេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៨-លោក | **ហ៊ុយ** | **យូស្រេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ៩-លោក | **ស៊ាង** | **តាំងឃាង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១០-លោក | **គង់** | **សៀកឡេង** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១១-លោក | **យូ** | **ជាង** | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ១២-លោក | **យូ** | **ម៉េងស៊្រី** | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.០០០ ដុល្លារ |

| | | | | |
|---|---|---|---|---|
| ១៣-លោក | ហម | [illegible]ង | សប្បុរសជននៅ[illegible]ត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៤-លោកស្រី | រស់ | ស៊ាងហេង | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៥-ឧបាសក | ជ | សម | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៦-ឧបាសក | ម៉ិត | ម៉ៅ | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៧-ឧបាសក | យុង | អូន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៨-លោក | សាន | ស្រ៊ុន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ១៩-លោក | អ៊ឹម | ទិទ្ធិរិទ្ធ | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២០-លោក | លាវ | អ៊ាងឌី | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២១-លោក | នុន | សារិទ្ធ | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២២-លោក | មិន | សារ៉េត | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៣-លោក | ស៊ាង | ស្រ៊ី | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៤-លោកស្រី | សេង | វណ្ណា | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៥-លោក | ឆាម | ស្រៀន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៦-លោក | ហ៊ុយ | គីមស្រ៊ាន | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៧-លោក | សំ | ឡុត | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៨-លោក | ស៊ុំ | ចេត | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ២៩-លោក | ឡេង | អ៊ាង | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ៣០-លោកស្រី | ឡោ | តាំងគីម | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ៣១-លោក | ឈិន | សុវណ្ណា | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ៣២-លោក | ម៉ិន | លាង | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ៣៣-លោកស្រី | គង់ | ម៉េះ | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |
| ៣៤-លោក | ឌូ | ម៉ៅ | សប្បុរសជននៅខេត្តកំពង់ចាម | ថវិកាចំនួន ១០.000 ដុល្លារ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ចាម និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ ៦ ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានន្តរស័ក្តិ និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែ មករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ដំឡើងឋានន្តរស័ក្តិលោក **ខូន រតនៈ** ពីឋានន្តរស័ក្តិ អនុមន្ត្រី ថ្នាក់លេខ ៨ ទៅជាឋានន្តរស័ក្តិ វរមន្ត្រី ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតែងតាំងជា **អភិបាលរង** នៃគណៈអភិបាលខេត្តបាត់ដំបង ។

**មាត្រា ២ :** ក្នុងរយៈពេលមកបំពេញភារកិច្ចក្នុងមុខតំណែងថ្មីខាងលើនេះ លោក **ខួន រតនៈ** ត្រូវដាក់ពាក្យស្នើសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ ៦ ឆ្នាំ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *រាជកិច្ច*
- *ឯកសារ កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៨០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ផ្ទេរបញ្ចូលទៅក្នុងឋានន្តរស័ក្តិ នាយក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ចំនួន **០២រូប** ដូចមានរាយនាមខាងក្រោម :

| ល.រ | នាមត្រកូល និងនាមខ្លួន | ឋានន្តរស័ក្តិ និងថ្នាក់ចាស់ | ឋានន្តរស័ក្តិ និងថ្នាក់ថ្មី |
|---|---|---|---|
| ១ | លោក **សុខ មករា** | ក្រមការ ថ្នាក់លេខ ៩ | នាយក្រមការ ថ្នាក់លេខ ៦ |
| ២ | លោក **សុខ សារិទ្ធ** | ក្រមការ ថ្នាក់លេខ ១៤ | នាយក្រមការ ថ្នាក់លេខ ៦ |

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៣*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *រាជកិច្ច*
- *ដូចមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៧១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក AHMAD MOHAMMED MAHMEUT ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងវិហារហាយ៉ាទុលឥស្លាម និងសមិទ្ធផលនានាមួយចំនួនទៀត នៅភូមិបឋមិននាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ចំណាយថវិកាអស់ចំនួន ៣៣.៦២៤ ដុល្លារអាមេរិក ។

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ៣៩៧ . អនក្រ . បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន១៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងវិហារ**ហាយ៉ាទុលឥស្លាម** និងសមិទ្ធផលនានាមួយចំនួនទៀតនៅភូមិបឋិននាវ សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ :**

១-លោកជំទាវ **ស្រ៊ិន ហ្វារ៉ូស** ភរិយាឯកឧត្តម វេជ្ជ. **ស្មះ មុះសិន** ថវិកាចំនួន ១២.០០០ ដុល្លារ

២-លោក **ហាំ ការីម** ថវិកាចំនួន ១០.០០០ ដុល្លារ

៣-លោក **ស្មះ ហ្វាស៊ី** ថវិកាចំនួន ១០.០០០ ដុល្លារ

៤-លោក **ម៉ាន សារី** ថវិកាចំនួន ១០.០០០ ដុល្លារ

៥-លោក **ម៉ូត ម៉ុស្តើត** ថវិកាចំនួន ១០.០០០ ដុល្លារ

៦-លោក **ស្មះ ស៊ុបអ៊ី** ថវិកាចំនួន ១០.០០០ ដុល្លារ

៧-លោក **ស្មាន ស្មាឯល** ថវិកាចំនួន ១០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ពាស់ តហេត** ថវិកាចំនួន ៦.០០០ ដុល្លារ

២-លោក **ពាស់ អះម៉ាត់** ថវិកាចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសិរីវឌ្ឍស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | **ម៉ាត់ មីន** | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ២-លោក | **អះម៉ាត់ កសឹម** | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៣-លោក | **ម៉ាត់ សឡេះ** | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៤-លោក | **ស្មាន ហ្សាក្រីយ៉ើ** | ថវិកាចំនួន | ១.៥០០ ដុល្លារ |
| ៥-លោក | **ហ៊ីម ការីម** | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៦-លោក | **យ៉េប ស្មាន** | ថវិកាចំនួន | ១.០០០ ដុល្លារ |
| ៧-លោក | **សុះ ណាសៀ** | ថវិកាចំនួន | ១.០០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៦ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៣៧៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតាំងស៊ប់ក្នុងក្របខ័ណ្ឌមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ១៣ រូប របស់ក្រសួងចំនួន ០៤ ទៅក្នុងឋានន្តរស័ក្តិក្រមការ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ដូចមាននាមរាយខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|---|---|
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១២ តទៅ | | | | | |
| ១ | **ជឹម ចាន់** | ប | ០៧-០៦-១៩៨៥ | ក្រមការ | ថ្នាក់លេខ ១២ |
| ២ | **ណាត វណ្ណៈ** | ប | ២៤-០៨-១៩៨៧ | ក្រមការ | ថ្នាក់លេខ ១២ |
| ៣ | **វន សារុំ** | ប | ១៣-០៤-១៩៨៦ | ក្រមការ | ថ្នាក់លេខ ១២ |
| ៤ | **នៅ រតនៈ** | ប | ១៥-០៥-១៩៨៨ | ក្រមការ | ថ្នាក់លេខ ១២ |
| **ក្រសួងពាណិជ្ជកម្ម** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ | | | | | |
| ១ | **ធី ឧត្តី** | ស | ១៥-០៤-១៩៨៩ | ក្រមការ | ថ្នាក់លេខ ១១ |
| ២ | **ប៉ាក ប៊ុនលី** | ប | ០៥-០៦-១៩៨៦ | ក្រមការ | ថ្នាក់លេខ ១១ |
| ៣ | **ឯក សេរីរត្នន៍** | ស | ០៦-០៥-១៩៨៨ | ក្រមការ | ថ្នាក់លេខ ១១ |
| ៤ | **ហង្ស សុជាតា** | ស | ០៤-១០-១៩៨៧ | ក្រមការ | ថ្នាក់លេខ ១១ |
| ៥ | **ហេង សមរតនា** | ប | ២១-០៩-១៩៨៩ | ក្រមការ | ថ្នាក់លេខ ១១ |
| ៦ | **ផន ស៊ីន** | ប | ០៣-០៧-១៩៨៦ | ក្រមការ | ថ្នាក់លេខ ១១ |
| **ក្រសួងធនធានទឹក និងឧតុនិយម** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ | | | | | |
| ១ | **ពៅ រតនា** | ប | ០៣-០៣-១៩៨៧ | ក្រមការ | ថ្នាក់លេខ ១២ |

| | | | | | |
|---|---|---|---|---|---|
| **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១២ តទៅ | | | | | |
| ១ | **សៀង ច័ន្ទសុខឡេ** | ប | ១២-០២-១៩៨៦ | ក្រមការ | ថ្នាក់លេខ ១១ |
| ២ | **មាស សារិទ្ធ** | ប | ២២-១២-១៩៨៦ | ក្រមការ | ថ្នាក់លេខ ១២ |

**មាត្រា ២ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌជូនមន្ត្រីរាជការចំនួន ០៩ រូប របស់ក្រសួងចំនួន ០២ ទៅក្នុងឋានន្តរស័ក្តិ មន្ត្រីបច្ចេកទេសមធ្យម នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសមធ្យម ដូចមានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និង នាម | ភេទ | ថ្ងៃខែឆ្នាំកំណើត | ឋានន្តរស័ក្តិ | ថ្នាក់ |
|---|---|---|---|---|---|
| **ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ | | | | | |
| ១ | **គ្មៀង ប្រាហ៊ុន** | ប | ០១-០៤-១៩៨៦ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ២ | **ថា ស៊ីថេន** | ប | ១០-០៧-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៣ | **ពាង សំអឿន** | ប | ១៤-០១-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៤ | **ម៉ៅ សុវ៉ានី** | ស | ០៣-០៣-១៩៨៣ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៥ | **ខួន សិរីរ័ត្ន** | ប | ០៥-០៨-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៦ | **ថេត ធីតា** | ស | ១០-០១-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ៧ | **ផាង ដូល្លា** | ប | ០៣-០៧-១៩៨៩ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| **ក្រសួងពាណិជ្ជកម្ម** | | | | | |
| តាំងស៊ប់ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៣ តទៅ | | | | | |
| ១ | **សួស បុប្ផា** | ស | ០៥-០១-១៩៩០ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |
| ២ | **ពេញ រិទ្ធី** | ប | ០៣-០៣-១៩៨៨ | មន្ត្រីបច្ចេកទេសមធ្យម | ថ្នាក់លេខ ១៤ |

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ និងមាត្រា ២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល*

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣៨៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនគ្រឿងឥស្សរិយយស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ប្រគេនគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ចំនួន **០៤គ្រឿង** ចំពោះព្រះតេជគុណដែលមានស្នាដៃក្នុងការរកធនធាន និងបរិច្ចាគបច្ច័យផ្ទាល់ខ្លួនចូលរួមចំណែកកសាងព្រះវិហារ និងកសាងសមិទ្ធផលនានាក្នុង**វត្តពោធិ៍លង្កា** ស្ថិតក្នុងឃុំកំពង់ព្រៀង ស្រុកសង្កែ ខេត្តបាត់ដំបង ដូចមានរាយព្រះនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះគ្រូ | **គីម កុសល** | សមុហ៍អនុគុណស្រុកសង្កែ និងជាចៅអធិការវត្តពោធិ៍លង្កា | បច្ច័យ ២៨.០០០ដុល្លារ |
| ២-ព្រះតេជគុណ | **សេង រុន** | ជំនួយការធម្មធរស្រុកសង្កែ និងជាចៅអធិការវត្តសេតពោធ្យារាម | បច្ច័យ ២៦.០០០ដុល្លារ |
| ៣-ព្រះតេជគុណ | **ឌុង ហ៊ាត** | ជំនួយការសមុហ៍អនុគុណស្រុកសង្កែ និងជាចៅអធិការវត្តអូរមណី | បច្ច័យ ២៦.០០០ដុល្លារ |
| ៤-ព្រះតេជគុណ | **ពេជ្រ សៀក** | លេខាធិការរង និងជាជំនួយការព្រះវិន័យធរគណ ខេត្តបាត់ដំបង | បច្ច័យ ២៦.០០០ដុល្លារ |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៨៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមាសការងារ** ជូននាយទាហាន នាយទាហានរង ចំនួន១៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ និងបានជួយឧបត្ថម្ភជាសម្ភារៈនិងថវិកា ដល់អង្គភាពកងពលតូចលេខ៧០ សម្រាប់កសាងអង្គភាពនាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១-វរសេនីយ៍ត្រី | **ជុំ** | **ទិន** | អត្តលេខ ០២០៩១១ | |
| ២-អនុសេនីយ៍ឯក | **សំ** | **តាស** | អត្តលេខ ០៥៦៣៤១ | នាយរងសុខាភិបាល |
| ៣-អនុសេនីយ៍ឯក | **ម៉ិច** | **សំអាត** | អត្តលេខ ០៣៩៣៤០ | នាយករងមន្ទីរពេទ្យ |
| ៤-អនុសេនីយ៍ឯក | **សុទ្ធ** | **សុវណ្ណារ៉ា** | អត្តលេខ ១៦២៤០៥ | ជំនួយការរដ្ឋបាល |
| ៥-អនុសេនីយ៍ឯក | **យ៉ុន** | **យឹម** | អត្តលេខ ០២០៩១៨ | ជំងឺទូទៅ |
| ៦-អនុសេនីយ៍ឯក | **ម៉ូហ៊ាង** | **លីហេង** | អត្តលេខ ២៣១៩០៥ | ជំងឺទូទៅ |
| ៧-អនុសេនីយ៍ឯក | **ម៉ាង** | **ឧត្តម** | អត្តលេខ ២៣១៥៣៦ | ជំងឺទូទៅ |
| ៨-អនុសេនីយ៍ឯក | **ហ៊ុន** | **ហឺន** | អត្តលេខ ០៨៤៥៣៤ | |
| ៩-អនុសេនីយ៍ទោ | **ថាយ** | **ទាសនា** | អត្តលេខ ២៣១៨៦៩ | |
| ១០-អនុសេនីយ៍ទោ | **សាំង** | **សារ៉ាយ** | អត្តលេខ ៧០០១៥៣ | ប្រធានផ្នែករដ្ឋបាល |
| ១១-អនុសេនីយ៍ត្រី | **ចាន់** | **ទេវី** | អត្តលេខ ១១០១០៧ | ជំងឺទូទៅ |

១២-អនុសេនីយ៍ត្រី **ខែម ស៊ីថា** អត្តលេខ ៧០០១៥៥ ផ្នែកជានា

១៣-អនុសេនីយ៍ត្រី **អ៊ឹម ទិជ្ជ័យ** អត្តលេខ ០៦៣៤២៥ ពលទាហានប្រចាំការតំបន់សេដ្ឋកិច្ចពិសេស

១៤-នាយចំណង់ **ទួច ម៉ា** អត្តលេខ ០៥៦១៩១

១៥-លោក **សេខ លំអខ** សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៦.អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### សម្រេច

**មាត្រា ១.-**

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនសប្បុរសជន ចំនួន១៣រូប ដែលបានជួយឧបត្ថម្ភជាសម្ភារៈ និងថវិកា ដល់អង្គភាពកងពលតូចលេខ៧០ សម្រាប់កសាងអង្គភាពនាពេលកន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | **ឡុង** | **ស៊ុធាទិន** | សប្បុរសជន |
| ២-លោកស្រី | **ឡុង** | **ចិន្តា** | សប្បុរសជន |
| ៣-លោក | **ឯម** | **យន** | សប្បុរសជន |
| ៤-លោក | **សម្បត្តិ** | **រតនាថាវី** | សប្បុរសជន |
| ៥-លោក | **អ៊ុក** | **ភន** | សប្បុរសជន |
| ៦-លោក | **ប៊ុន** | **ឫ** | សប្បុរសជន |
| ៧-លោក | **ទ្រឿង** | **មករា** | សប្បុរសជន |
| ៨-កញ្ញា | **ខ្លូត** | **វល័ក្ខណ៍** | សប្បុរសជន |
| ៩-លោក | **កែវ** | **សន្តិភាព** | សប្បុរសជន |
| ១០-កញ្ញា | **ពិន** | **លក្ខិណា** | សប្បុរសជន |
| ១១-កញ្ញា | **រស់** | **សុខរ៉ាន** | សប្បុរសជន |
| ១២-អ្នកស្រី | **ប្រាជ្ញ** | **ណារី** | សប្បុរសជន |
| ១៣-អ្នកស្រី | **សម** | **មួយ** | សប្បុរសជន |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មករា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៨៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ផ្តល់ជូនលោក **BAIK YOUNG CHANG** ប្រធានក្រុមហ៊ុន HAPDONG EXPRESS GROUP ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយឈូសឆាយ និងជួសជុលផ្លូវលំជាច្រើនកន្លែង នៅក្នុងឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ។

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបាត់ដំបង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៥៥ .អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

# រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥២អនក្រ.បក ចុះថ្ងៃទី២១ខែកញ្ញាឆ្នាំ២០១២ ស្តីពីការបង្កើតវិទ្យាស្ថានប្រវត្តិសាស្ត្រយោធា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

១-ឧត្តមសេនីយ៍ទោ **គឹម វណ្ណសារ៉ុម** អត្តលេខ ០០២២៤០ ជា ទីប្រឹក្សា ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ត្រី **ឡឿង សារឿន** អត្តលេខ ០០២២៥២ ជា នាយក មហាវិទ្យាល័យបញ្ជាការសេនាធិការ សាកលវិទ្យាល័យការពារជាតិ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...០៣...សរ.

# សារាចរ

## ស្តីពី

## ការអនុវត្តគោលការណ៍ណែនាំអំពីនីតិវិធីនិងវិធាននៃការតាក់តែង សេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

កន្លងមករាជរដ្ឋាភិបាលបានសង្កេតឃើញថា ក្រសួង ស្ថាប័នទាំងអស់បានខិតខំរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទាក់ទងនឹងជំនាញរបស់ខ្លួន ហើយផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី សុំឆ្លងអង្គប្រជុំជំនាញបច្ចេកទេស អង្គប្រជុំអន្តរក្រសួង អង្គប្រជុំត្រួតពិនិត្យជាចុងក្រោយ និងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីសុំការយល់ព្រមនិងបញ្ជូនទៅសុំការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិឬស្នើសុំព្រះរាជតម្រិះពីព្រះមហាក្សត្រឬការសម្រេចពីនាយករដ្ឋមន្ត្រី ក្នុងគោលបំណងចូលរួមពង្រឹងនីតិរដ្ឋឱ្យកាន់តែប្រសើរថែមទៀត។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានសង្កេតឃើញដែរថា ការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់ក្រសួង ស្ថាប័ននៅពុំទាន់មានឯកភាពស៊ីចង្វាក់គ្នាបានល្អនិងរលូននៅឡើយ។ ដើម្បីឱ្យការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតមានឯកភាព រាជរដ្ឋាភិបាលដាក់ចេញនូវនីតិវិធីនិងវិធាននៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តទាំងនោះនិងធ្វើការណែនាំដូចតទៅ៖

១- គ្រប់ក្រសួង ស្ថាប័នត្រូវពង្រឹងនិងជំរុញអង្គភាពនីតិកម្មក្រោមឱវាទឱ្យដំណើរការបានសកម្មក្នុងការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដោយសហការជាមួយនាយកដ្ឋានជំនាញរបស់ក្រសួង ស្ថាប័នរៀងៗខ្លួន។

២- នៅដើមត្រីមាសទី៤នៃឆ្នាំនីមួយៗ គ្រប់ក្រសួង ស្ថាប័នត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតដែលទទួលបានកន្លងមក និងត្រូវផ្ញើគម្រោងកម្មវិធីនៃតម្រូវការសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលក្រសួង ស្ថាប័ននីមួយៗត្រូវការរៀបចំ ដើម្បីបំពេញការអនុវត្តច្បាប់ឬតម្រូវការសម្រាប់ដំណើរការការងាររបស់

ខ្លួនឱ្យមានប្រសិទ្ធភាពសម្រាប់ឆ្នាំខាងមុខ។ គម្រោងកម្មវិធីនេះត្រូវផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីយ៉ាងយូរនៅដំណាច់ខែវិច្ឆិកានៃឆ្នាំនីមួយៗ។

៣- ផ្អែកលើគម្រោងកម្មវិធីនៃតម្រូវការសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតរបស់ក្រសួង ស្ថាប័ន នៅដំណាច់ឆ្នាំនីមួយៗដោយមានកំណត់កាលបរិច្ឆេទនៃការប្រគល់មកទីស្តីការគណៈរដ្ឋមន្ត្រីនូវសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងសម្រេចនូវបញ្ជីស្តីពីកម្មវិធីនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល ដោយអនុលោមទៅតាមកាតព្វកិច្ចដែលត្រូវបំពេញតាមរដ្ឋធម្មនុញ្ញឬកាតព្វកិច្ចដែលត្រូវបំពេញដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌនៃអង្គការអន្តរជាតិនានាដែលព្រះរាជាណាចក្រកម្ពុជាជាសមាជិក។

៤- បន្ទាប់ពីទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីលើកម្មវិធីនៃការរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត គ្រប់ក្រសួង ស្ថាប័នត្រូវរៀបចំសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តទាំងនោះ ដោយអនុវត្តតាមគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដូចមានជាប់មកជាមួយ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័នត្រូវផ្សព្វផ្សាយនិងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលថ្មី

***( ត មកពីរាជកិច្ចលេខ ៤៧ )***

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

# ព្រះរាជក្រឹត្យ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហានាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី... ខែ... ឆ្នាំ...
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី... នីតិកាលទី...នៃរដ្ឋសភា នាថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធនិងថ្នាក់ដឹកនាំនៃរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ .-**

ត្រូវបានបញ្ចប់តំណែងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/... (លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ហើយដែលបានកែសម្រួលដោយព្រះរាជក្រឹត្យជាបន្តបន្ទាប់មុនថ្ងៃទី... ខែ... ឆ្នាំ... និងតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចតទៅ៖

**I- នាយករដ្ឋមន្ត្រី**

....................

**II- ឧបនាយករដ្ឋមន្ត្រី**

១- ឯកឧត្តម ...

២- ឯកឧត្តម ...

៣- ឯកឧត្តម ...

៤- ឯកឧត្តម ...

**III- ទេសរដ្ឋមន្ត្រី**

១- ឯកឧត្តម ...

២- ឯកឧត្តម ...

៣- ឯកឧត្តម ...

៤- ឯកឧត្តម ...

**IV-ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន**(ក្នុងចំណុចនេះ ត្រូវរាយឈ្មោះក្រសួងតាមលំដាប់លំដោយនៃឋានានុក្រមរបស់ប្រធានស្ថាប័ន ដែលជាឧបនាយករដ្ឋមន្ត្រីផងឬជាទេសរដ្ឋមន្ត្រីផង ក្រោមទីស្តីការគណៈរដ្ឋមន្ត្រី និងត្រូវពិនិត្យដាក់ឈ្មោះក្រសួងឱ្យបានត្រឹមត្រូវ ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតក្រសួង)

**១- ទីស្តីការគណៈរដ្ឋមន្ត្រី**

- **រដ្ឋមន្ត្រី** : ឯកឧត្តម ...
- **រដ្ឋលេខាធិការ** : ឯកឧត្តម ...
- : ឯកឧត្តម ...

**២- ក្រសួង...**

- **រដ្ឋមន្ត្រី** : ឯកឧត្តម ...
- **រដ្ឋលេខាធិការ** : ឯកឧត្តម ...
- : ឯកឧត្តម ...

..........................................................................................................................

- **រដ្ឋលេខាធិការដ្ឋាន**... (ចំណុះគណៈរដ្ឋមន្ត្រីតាមច្បាប់)
  - **រដ្ឋលេខាធិការ** : ឯកឧត្តម ...

**V- រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី**

**១- រដ្ឋលេខាធិការដ្ឋាន...**

- **រដ្ឋលេខាធិការ** : ឯកឧត្តម ...

**២- រដ្ឋលេខាធិការដ្ឋាន...**

- **រដ្ឋលេខាធិការ** : ឯកឧត្តម ...។

**មាត្រា២ .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ... ខែ ... ឆ្នាំ ... ឬ

ធ្វើនៅថ្ងៃទី ... ខែ ... ឆ្នាំ ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការដំឡើង
ឋានន្តរសក្តិឬថ្នាក់ ការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការ...

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

# ព្រះរាជក្រឹត្យ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីលក្ខន្តិកៈដោយឡែកនៃ...(ឈ្មោះក្របខ័ណ្ឌរបស់មន្ត្រីសាមី)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី..(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ចំពោះព្រះរាជក្រឹត្យស្តីពីការតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖

ត្រូវបានតាំងស៊ប់លោក ... អត្តលេខ...(បើមាន) ក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...។

២- លោក... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការតែងតាំងមន្ត្រីរាជការដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ... ជំនួសឯកឧត្តម... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសឯកឧត្តម ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសឯកឧត្តម ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ ... ឱ្យបំពេញមុខងារជា... នៅ... ជំនួសឯកឧត្តម ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... ជំនួសឯកឧត្តម ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... ជំនួសឯកឧត្តម ... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការតែងតាំងមន្ត្រីរាជការ ដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យសម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ...។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យ សម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ ... ឱ្យបំពេញមុខងារជា... នៅ...។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ(ផ្ទៃក្នុង) ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្ទេរភារកិច្ចឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា... (មុខតំណែង) នៅ...។ ឬ

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា... (មុខតំណែង)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា... (មុខតំណែង)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដំឡើងឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរសក្តិឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ ឬ

ត្រូវបានដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។ ឬ

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដែលបាន...(ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការបន្ថយឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយឋានន្តរសក្តិឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានបន្ថយឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

ចំពោះព្រះរាជក្រឹត្យស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការតាមវេនជ្រើសរើសនិងវេនអតីតភាពត្រូវចែងដូចតទៅ៖

ត្រូវបានដំឡើងថ្នាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការ ដែលទទួលបានសញ្ញាបត្រខ្ពស់ជាងការកំណត់ក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងថ្នាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព។ ឬ

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការបន្ថយថ្នាក់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយថ្នាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានបន្ថយថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដកមន្ត្រីរាជការពីមុខតំណែង ត្រូវចែងដូចតទៅ៖**

ត្រូវបានដកឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចេញពីមុខតំណែង... ដោយមូលហេតុ... ។ ឬ

ត្រូវបានដកមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង ... ដោយមូលហេតុ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង ... ដោយមូលហេតុ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**ចំពោះព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី...ខែ...ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបញ្ចប់ភារកិច្ចឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ (បើជាមន្ត្រីមានក្របខ័ណ្ឌ)។ ឬ

ត្រូវបានបញ្ចប់ភារកិច្ចមន្ត្រីរាជការឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

**ចំពោះព្រះរាជក្រឹត្យស្តីពីការលុបឈ្មោះឬបញ្ឈប់មន្ត្រីរាជការពីការងារ ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍មុនកំណត់ (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីការដាក់មន្ត្រីរាជការដែលកាន់តំណែងនយោបាយឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈដោយរក្សាមុខតំណែងនយោបាយ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាមុខតំណែងនយោបាយ ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី ... ខែ... ឆ្នាំ...។

២- ឯកឧត្តម ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី ... ខែ... ឆ្នាំ...។

**ចំពោះព្រះរាជក្រឹត្យស្តីពីសមាហរណកម្មមន្ត្រីរាជការក្នុងក្របខ័ណ្ឌប្រភេទ ក ត្រូវចែងដូចតទៅ៖**

ត្រូវបានធ្វើសមាហរណកម្មលោក ... ទៅក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន) នៅ...។ ឬ

ត្រូវបានធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

២- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

(មាត្រានេះមិនត្រូវចែងទេក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

# ព្រះរាជក្រឹត្យ
# ស្តីពី

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ... (ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្មដល់លោក ... (ឈ្មោះជាអក្សរខ្មែរនិងអក្សរឡាតាំង) សញ្ជាតិដើម... កើតថ្ងៃទី... ខែ... ឆ្នាំ... នៅ...(ឈ្មោះទីក្រុងនិងប្រទេស)។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។
(មាត្រានេះមិនត្រូវចែងទេក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោសនិងលើកលែងទោស

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ក្រឹត្យលេខ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១.-**

ត្រូវបានបន្ធូរបន្ថយទោសនិងលើកលែងទោសឱ្យទណ្ឌិត ដូចតទៅៈ

ក- បន្ថយរយៈពេលទទួលរងទោស១២ខែឱ្យទណ្ឌិតចំនួន...នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលទទួលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះៈ

១- ទណ្ឌិតឈ្មោះ ... ភេទ... អាយុ... ត្រូវបានចាប់ខ្លួននៅថ្ងៃទី... ពីបទ... ហើយត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារកំណត់... តាមអំណាចសាលក្រម/សាលដីកាលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់តុលាការ...។

២- ទណ្ឌិតឈ្មោះ ... ភេទ... (ដូចក្នុងចំណុច១)។

ខ- បន្ថយរយៈពេលទទួលរងទោស៩ខែឱ្យទណ្ឌិតចំនួន...នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលទទួលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយនាមខាងក្រោមនេះៈ

១- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក)។

២- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក)។

គ- បន្ថយរយៈពេលទទួលរងទោស៦ខែឱ្យទណ្ឌិតចំនួន...នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលទទួលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះៈ

១- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក )។

២- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក )។

**ឃ-** លើកលែងទោសឱ្យទណ្ឌិតចំនួន...នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលទទួលរងទោស ក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ៖

១- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក )។

២- ទណ្ឌិតឈ្មោះ ... (ដូចក្នុងចំណុច ក )។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

(មាត្រានេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

**(ព្រះបរមនាម)**

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការតែងតាំងចៅក្រម

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

# ព្រះរាជក្រឹត្យ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ហោរតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៩/នស/៩៤ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានការឯកភាពពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នាសម័យប្រជុំថ្ងៃទី... ខែ... ឆ្នាំ...

**ត្រាស់បង្គាប់**

**មាត្រា១ .-**

ត្រូវបានតែងតាំងៈ

១- លោក ... ... (តួនាទីបច្ចុប្បន្ន)ជា...

២- លោក ... ... (តួនាទីបច្ចុប្បន្ន)ជា...។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

(មាត្រានេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ...(ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការតែងតាំងព្រះគោរមងារឬព្រះឋានានុក្រមមន្ត្រីសង្ឃ

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ .-**

ត្រូវបានតែងតាំងមន្ត្រីសង្ឃនៃគណៈ...នៃព្រះរាជាណាចក្រកម្ពុជា ដូចមានរាយព្រះនាមខាងក្រោម៖

១- (ព្រះគោរមងារ) ព្រះនាម...(ព្រះឋានានុក្រម) ជា(ព្រះគោរមងារ) ព្រះនាម...(ព្រះឋានានុក្រម)

២- (ព្រះគោរមងារ) ព្រះនាម...(ព្រះឋានានុក្រម) ជា(ព្រះគោរមងារ) ព្រះនាម...(ព្រះឋានានុក្រម)។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

(មាត្រានេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

(ព្រះហស្ថលេខានិងព្រះរាជលញ្ឆករ)
(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការប្រទានគ្រឿងឥស្សរិយយសចំពោះបុគ្គល

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

**ចំពោះ**

ឯកឧត្តម ... (**ឈ្មោះ**)

នូវ

គ្រឿងឥស្សរិយយស... (**ឈ្មោះ**) ថ្នាក់... (**កម្រិត**)

(ព្រះហស្តលេខានិងព្រះរាជលញ្ចករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការប្រទានគ្រឿងឥស្សរិយយសជាក្រុម

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រោសព្រះរាជទាន**

នូវ

ក- គ្រឿងឥស្សរិយយស... (**ឈ្មោះ**) ថ្នាក់...(**កម្រិត**) ចំពោះ៖

១- ឯកឧត្តម ... (**ឈ្មោះ**)

២- ឯកឧត្តម ... (**ឈ្មោះ**)

ខ- គ្រឿងឥស្សរិយយស... (**ឈ្មោះ**) ថ្នាក់...(**កម្រិត**) ចំពោះ៖

១- ឯកឧត្តម ... (**ឈ្មោះ**)

២- ឯកឧត្តម ... (**ឈ្មោះ**)

(ព្រះហស្តលេខានិងព្រះរាជលញ្ជករ)

(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ

ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការតែងតាំង(ឬប្រទានងារ)អ្នកឧកញ៉ាឬឧកញ៉ា

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**តែងតាំង**

ឯកឧត្តម ... (ឈ្មោះ)

**ជា**

**អ្នកឧកញ៉ាឬឧកញ៉ា**

(ចំពោះងារអាស្រ័យព្រះមហាក្សត្រប្រទាន)

(ព្រះហស្តលេខានិងព្រះរាជលញ្ចករ)
(**ព្រះបរមនាម**)

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីព្រះមហាក្សត្រមិនគង់នៅព្រះបរមរាជវាំង)

គំរូទម្រង់នៃព្រះរាជក្រឹត្យជាសំណៅនិងសំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...

# ត្រាស់បង្គាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

..................................................................................................................................។

## ជំពូកទី២ និង ជំពូកបន្តបន្ទាប់
(ចំណងជើង)

**មាត្រា... .-**

..................................................................................................................................។

## ជំពូកទី...
## អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

..................................................................................................................................។

## ជំពូកទី...
## អវសានប្បញ្ញត្តិ

**មាត្រា... .-**

ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករព្រះរាជក្រឹត្យចាស់ទាំងស្រុង)ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីព្រះរាជក្រឹត្យថ្មីឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់ព្រះរាជក្រឹត្យចាស់)

**មាត្រា... .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ... ( ក្នុងករណីព្រះមហាក្សត្រ
មិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)
(**ព្រះបរមនាម**)

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
(ហត្ថលេខា)
(**គោរមងារនិងឈ្មោះ**)

លេខ : ...

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

លេខ : ...

**បានចម្លងត្រឹមត្រូវតាមសំណៅ**

**ដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**ត.ប. រដ្ឋមន្ត្រី**

**អគ្គលេខាធិការឬអគ្គនាយក...**

(ហត្ថលេខានិងត្រា)

(**ឈ្មោះ**)

**កន្លែងទទួល** :

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋាន
- អគ្គាធិការដ្ឋាន
- នាយកដ្ឋាន
- មន្ទីរជំនាញរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

### ៣.២.៦- ទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ

ទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត នៅផ្នែកនេះមានព្រះរាជសង្ហាររបស់ព្រះមហាក្សត្រ នៅចំកណ្តាលទំព័រក្រោមព្រះរាជសង្ហាររបស់ព្រះមហាក្សត្ររំលង១បន្ទាត់ ត្រូវដាក់ពាក្យ **ព្រះរាជក្រឹត្យ** ក្រោមពាក្យព្រះរាជក្រឹត្យ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យស្តីពី ដាក់**ការកែសម្រួលមាត្រា...នៃព្រះរាជក្រឹត្យលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី** និងជាបន្តមកទៀតដាក់ចំណងជើងនៃព្រះរាជក្រឹត្យដែលត្រូវធ្វើការកែសម្រួល។ នៅក្រោមចំកណ្តាលពាក្យព្រះរាជក្រឹត្យដាក់ពាក្យ **យើង** ហើយនៅពីក្រោមនេះ សរសេរព្រះគោរមងាររបស់ព្រះមហាក្សត្រ។

ខ- មូលបទ ត្រូវយោងជាចាំបាច់នូវរដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ព្រះរាជក្រម និងព្រះរាជក្រឹត្យទាំងឡាយដែលពាក់ព័ន្ធមានជាអាទិ៍ ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង ស្ថាប័ន ព្រះរាជក្រឹត្យដើម និងចុងក្រោយនៃមូលបទមានដាក់សេចក្តីដូចខាងក្រោម៖

- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ... (ចំពោះព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ មានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី) ឬ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា (ចំពោះព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ មានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី)។

បន្ទាប់ពីនេះ នៅខាងក្រោមចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ៖

**ត្រាស់បង្គាប់**

គ- ខ្លឹមសារនៃអត្ថបទ

ព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ មានតែ៣មាត្រាប៉ុណ្ណោះ។

**មាត្រាមួយ** ត្រូវចែងពីមាត្រាទាំងឡាយដែលត្រូវធ្វើការកែសម្រួល ក្នុងនោះត្រូវចែងមាត្រាថ្មីដែលកែប្រែខ្លឹមសារមាត្រាចាស់ដោយដាក់ស្មើនឹងមាត្រាមួយដែរ។

**មាត្រាពីរ** ត្រូវចែងពីការនិរាករនិងត្រូវចែងចំពោះតែករណីចាំបាច់ដែលត្រូវនិរាករជាស្ថាពរនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដែលផ្ទុយនឹងព្រះរាជក្រឹត្យប៉ុណ្ណោះ។

**មាត្រាបី** ត្រូវចែងពីបទប្បញ្ញត្តិស្តីពីការត្រាស់បង្គាប់ឱ្យនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអនុវត្តព្រះរាជក្រឹត្យចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ហើយមិនត្រូវចែងបន្ថែមមាត្រាមួយទៀតថា "ព្រះរាជក្រឹត្យនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ "ឡើយ។

ឃ- *រូបមន្តបញ្ចប់* ព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យត្រូវបានឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រឬចុះហត្ថលេខាដោយប្រមុខរដ្ឋស្តីទី។ ចំពោះព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី មានតែហត្ថលេខាអមរបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។ ចំពោះព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមីដើម្បីជាអ្នកស្នើឡើងថែមទៀត។

អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ត្រូវពិនិត្យមើលរាល់សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យឱ្យបានត្រឹមត្រូវតាមទម្រង់ខាងលើ មុននឹងដាក់ជូននាយករដ្ឋមន្ត្រីចុះហត្ថលេខាលើលិខិតថ្វាយព្រះមហាក្សត្រដើម្បីសូមឡាយព្រះហស្តលេខា។

ក្រសួងព្រះបរមរាជវាំងចុះលេខព្រះរាជក្រឹត្យ ដោយដាក់សញ្ញាសម្គាល់អក្សរកាត់តាមរូបមន្ត **នស/រកត/** ...(លេខខែឆ្នាំ)/...(លេខព្រះរាជក្រឹត្យ) ចុះកាលបរិច្ឆេទ ប្រថាប់ព្រះរាជលញ្ឆករ និងចុះលេខព្រះរាជលញ្ឆករ ព្រមទាំងបោះត្រារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំងលើគ្រប់សន្លឹកទំព័រនៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ លើកលែងតែទំព័រចុងក្រោយដែលមានព្រះរាជលញ្ឆកររួចហើយ។

សូមមើលគំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ មានលក្ខណៈជាបទបញ្ជាទូទៅដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទំព័រទី៦៥និង៦៦ និងគំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យ មានលក្ខណៈជាបទបញ្ជាទូទៅដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី នៅទំព័រទី៦៧និង៦៨។

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ
ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា...នៃព្រះរាជក្រឹត្យលេខ...**

**ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី**

(ចំណងជើងនៃព្រះរាជក្រឹត្យដែលត្រូវធ្វើការកែសម្រួលជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមីដែលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ...

## ត្រាស់បង្គាប់

**មាត្រាមួយ ._**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើការកែសម្រួល)នៃព្រះរាជក្រឹត្យលេខ នស/រកត/... /... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃព្រះរាជក្រឹត្យ) ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា**... (លេខមាត្រាដែលត្រូវធ្វើការកែសម្រួល) **._ ថ្មី**

.....................................................................................................................................

.....................................................................................................................................។

**មាត្រាពីរ ._**

ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករព្រះរាជក្រឹត្យចាស់ទាំងស្រុង)ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីព្រះរាជក្រឹត្យថ្មីឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់ព្រះរាជក្រឹត្យចាស់)

**មាត្រាបី ._**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ... ( ក្នុងករណីព្រះមហាក្សត្រ
មិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ឆករ)

( **ព្រះបរមនាម** )

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
(ហត្ថលេខា)
( **គោរមងារនិងឈ្មោះ** )

គំរូទម្រង់នៃព្រះរាជក្រឹត្យស្តីពីការកែសម្រួលព្រះរាជក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅដែលមិនបានឆ្លង
អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

△

(រូបសញ្ញាព្រះរាជសង្ហារព្រះមហាក្សត្រ)

**ព្រះរាជក្រឹត្យ**

**ស្តីពី**

**ការកែសម្រួលមាត្រា...នៃព្រះរាជក្រឹត្យលេខ...**

**ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី**

(ចំណងជើងនៃព្រះរាជក្រឹត្យដែលត្រូវធ្វើការកែសម្រួលជាអក្សរមូល)

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ការកែសម្រួលសមាសភាពសមាជិករាជរដ្ឋាភិបាល(ដែលទាក់ទងនឹងរដ្ឋមន្ត្រីឬប្រធានស្ថាប័នសាមី ដែលរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យ)
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ .-**

មាត្រា...(លេខមាត្រាដែលត្រូវធ្វើការកែសម្រួល)នៃព្រះរាជក្រឹត្យលេខ នស/រកត/... /... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ចំណងជើងនៃព្រះរាជក្រឹត្យ) ត្រូវបានធ្វើការកែសម្រួលដូចតទៅ៖

**មាត្រា**... (លេខមាត្រាដែលត្រូវធ្វើការកែសម្រួល) **.- ថ្មី**

........................................................................................................................................

........................................................................................................................................។

**មាត្រាពីរ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករព្រះរាជក្រឹត្យចាស់ទាំងស្រុង)ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីព្រះរាជក្រឹត្យថ្មីឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់ព្រះរាជក្រឹត្យចាស់)

**មាត្រាបី .-**

(គោរមងារ)នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី... ខែ... ឆ្នាំ... ឬ
ធ្វើនៅ ថ្ងៃទី... ខែ... ឆ្នាំ... ( ក្នុងករណីព្រះមហាក្សត្រ
មិនគង់នៅព្រះបរមរាជវាំង)

(ព្រះហស្តលេខានិងព្រះរាជលញ្ចករ)

**( ព្រះបរមនាម )**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
(ហត្ថលេខា)
**( គោរមងារនិងឈ្មោះ )**

បានយកសេចក្តីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួង**...ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័នសាមី)
(ហត្ថលេខា)
**( ឈ្មោះ )**

**៣.២.៧- ទម្រង់នៃអនុក្រឹត្យ អនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យ សេចក្តីសម្រេច និងសារាចររបស់រាជរដ្ឋាភិបាល**

**៣.២.៧.១- ទម្រង់នៃអនុក្រឹត្យ**

អនុក្រឹត្យ ជាលិខិតបទដ្ឋានគតិយុត្តចេញដោយប្រមុខរាជរដ្ឋាភិបាល។ អនុក្រឹត្យមានពីរប្រភេទគឺ អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅនិងអនុក្រឹត្យមានលក្ខណៈជាឯកត្តភូត។

អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ជាការណែនាំការអនុវត្តឬបញ្ជាក់បន្ថែមខ្លឹមសាររបស់ច្បាប់និងព្រះរាជក្រឹត្យ ជាការណែនាំការអនុវត្តកិច្ចការនានារបស់ក្រសួង ស្ថាប័ននីមួយៗ ឬការអនុវត្តកិច្ចការទាំងឡាយណាដែលមានទំនាក់ទំនងជាអន្តរក្រសួង ជាការបង្កើតគណៈកម្មាធិការ ដូចជាអនុក្រឹត្យស្តីពីនីតិវិធីនៃការអនុវត្តវិន័យចំពោះមន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន និងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរាជាដើម។

អនុក្រឹត្យមានលក្ខណៈជាឯកត្តភូត ជាអនុក្រឹត្យដែលទាក់ទងឬសំដៅចំឈ្មោះបុគ្គល។ អនុក្រឹត្យប្រភេទនេះ មានដូចជាអនុក្រឹត្យស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការតែងតាំង ការប្រគល់ភារកិច្ច ការផ្ទេរភារកិច្ច ការដំឡើងឋានន្តរសក្តិ ការបន្ថយឋានន្តរសក្តិ ការដំឡើងថ្នាក់ ការបន្ថយថ្នាក់ ការដកពីមុខតំណែង ការអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ការអនុញ្ញាតឬការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ការអនុញ្ញាតឱ្យចូលបម្រើការងារឡើងវិញ ការបញ្ចប់ភារកិច្ច ការលុបឈ្មោះឬការបញ្ឈប់ពីការងារ ការដាក់ឱ្យចូលនិវត្តន៍ ការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលក្នុងក្របខ័ណ្ឌប្រភេទ ខ ការផ្តល់គ្រឿងឥស្សរិយយសចំពោះបុគ្គលឬជាក្រុមជាដើម។

ទម្រង់នៃអនុក្រឹត្យចែកចេញជា៤ផ្នែក មានក្បាលលិខិត មូលបទ ខ្លឹមសារនៃអត្ថបទ និងរូបមន្តបញ្ចប់។

ក- ក្បាលលិខិត ត្រូវប្រើក្រដាសក្បាលលិខិតរបស់រាជរដ្ឋាភិបាល ដែលមានសញ្ញាជាតិ(ដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)នៅខាងលើចំកណ្តាលទំព័រ ក្រោមសញ្ញាជាតិ ដាក់ឈ្មោះប្រទេស **ព្រះរាជាណាចក្រកម្ពុជា** ក្រោមឈ្មោះប្រទេស ដាក់បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ប៉ែកខាងឆ្វេងស្មើនឹងបន្ទាត់បាវចនា ត្រូវដាក់ **រាជរដ្ឋាភិបាលកម្ពុជា** ក្រោម រាជរដ្ឋាភិបាលកម្ពុជា ដាក់ពាក្យ **លេខ** :... សម្រាប់ទុកចុះលេខរបស់អនុក្រឹត្យដែលមានរូបមន្តអក្សរកាត់ដូចតទៅ៖

- បើជាអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ គឺ **លេខ** :... អនក្រ.បក (បក = បង្កើត)
- បើជាអនុក្រឹត្យមានលក្ខណៈជាឯកត្តភូត គឺ **លេខ** :... អនក្រ.តត (តត = តែងតាំង)

នៅក្រោមបាវចនា រំលង១បន្ទាត់ ចំកណ្តាលទំព័រ ត្រូវដាក់ពាក្យ **អនុក្រឹត្យ** ក្រោមពាក្យ អនុក្រឹត្យ ដាក់ពាក្យ **ស្តីពី** ក្រោមពាក្យ ស្តីពី ដាក់ចំណងជើងនៃអនុក្រឹត្យ។

នៅក្រោមចំណងជើង ចំកណ្តាលរំលង១បន្ទាត់ ត្រូវដាក់ **រាជរដ្ឋាភិបាល**។

ខ- មូលបទ ត្រូវជ្រើសរើសយោងតែលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងខ្លឹមសារនៃអនុក្រឹត្យ ហើយសរសេរដោយប្រើពាក្យ បានឃើញ។ លិខិតបទដ្ឋានគតិយុត្តដែលត្រូវយោងក្នុងអនុក្រឹត្យ មានជាអាទិ៍ រដ្ឋធម្មនុញ្ញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាល ព្រះរាជក្រមដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ហើយអាចយោងកិច្ចព្រមព្រៀងឬអនុសញ្ញាអន្តរជាតិនានា ក្នុងករណីចាំបាច់។

នៅចុងក្រោយបង្អស់នៃមូលបទ ត្រូវយោងតាមករណីនីមួយៗនៃសេចក្តី ដោយចែងដូចខាងក្រោម៖

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី) ឬ

- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល(ក្នុងករណីសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល) ឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)។

ជាគោលការណ៍ អនុក្រឹត្យមិនមានយោងលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមទាបជាងឡើយ។

នៅខាងក្រោមចំកណ្តាលទំព័រ ត្រូវសរសេរពាក្យ៖

**សម្រេច**

**គ- ខ្លឹមសារនៃអត្ថបទ**

គ.១- អនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ អាចចែកជា ជំពូកទី១ ជំពូកទី២ និងជំពូកបន្តបន្ទាប់។ ជាទូទៅ ជំពូកទី១ អាចចែងអំពីគោលបំណង គោលដៅ វិសាលភាព និងនិយមន័យនៃពាក្យសំខាន់ៗតាមការចាំបាច់។ ប៉ុន្តែនិយមន័យអាចចែងក្នុងឧបសម្ព័ន្ធបាន។

ជំពូកស្តីពីអវសានប្បញ្ញត្តិ ចែងពីការនិរាករលិខិតបទដ្ឋានគតិយុត្តនិងបទប្បញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ។ ចំពោះមាត្រាបញ្ចប់ ត្រូវចែងពីការប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំឬស្នើ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដែលត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

សូមមើលគំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល នៅទំព័រទី៧២និង៧៣ គំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី នៅទំព័រទី៧៤ដល់៧៦ និងគំរូទម្រង់នៃអនុក្រឹត្យស្តីពីការទទួលស្គាល់ នៅទំព័រទី៧៧និង៧៨។

គ.២- អនុក្រឹត្យមានលក្ខណៈជាឯកត្តភូត ជាទូទៅមានតែ២ឬ៣មាត្រាប៉ុណ្ណោះ។

គ.២.១- **ខ្លឹមសារដែលត្រូវចែងក្នុងមាត្រា១** ត្រូវតែងដោយប្រែប្រួលទៅតាមកម្មវត្ថុនិងគោលបំណងជាក់ស្តែង ដែលមានរូបមន្តដូចក្នុងគំរូទម្រង់នៃអនុក្រឹត្យ។

**គ.២.២- ខ្លឹមសារក្នុងមាត្រាបន្ទាប់និងមាត្រាបញ្ចប់**

ខ្លឹមសារនៃមាត្រាដែលចែងពីការនិរាករ ត្រូវចែងតែចំពោះករណីចាំបាច់ដែលត្រូវនិរាករជាស្ថាពរនូវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលផ្ទុយនឹងអនុក្រឹត្យតែប៉ុណ្ណោះ។ មាត្រាដែលត្រូវចែងពីការនិរាករ និងមាត្រាបញ្ចប់ ត្រូវចែងដូចមានខ្លឹមសារក្នុងគំរូទម្រង់នៃអនុក្រឹត្យ។

សូមមើលគំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាឯកត្តភូត នៅទំព័រទី៧៩ដល់៨៦។

**ឃ- រូបមន្តបញ្ចប់** នៅខាងក្រោមប៉ែកខាងស្តាំ ត្រូវចុះទីកន្លែង កាលបរិច្ឆេទ ហត្ថលេខាគោរមងារ និងឈ្មោះរបស់នាយករដ្ឋមន្ត្រីឬរបស់នាយករដ្ឋមន្ត្រីស្តីទី នៅពេលដែលនាយករដ្ឋមន្ត្រីអវត្តមាន និងបោះត្រារបស់រាជរដ្ឋាភិបាល។ ចំពោះអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីឬសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល មានតែហត្ថលេខារបស់នាយករដ្ឋមន្ត្រីប៉ុណ្ណោះ។ ចំពោះអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅ ដែលមិនបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី ត្រូវមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នសាមីដែលជាអ្នកស្នើឡើងថែមទៀត។ ប្រសិនបើជាអនុក្រឹត្យមានលក្ខណៈជាឯកត្តភូត មិនមានហត្ថលេខាអមរបស់រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័នទេ។

នៅប៉ែកខាងឆ្វេងទំព័រ ត្រូវដាក់ **កន្លែងទទួល** ដែលរួមមានក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការរាជរដ្ឋាភិបាល

ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី ដូចមាត្រា...(ពាក់ព័ន្ធនឹងក្រសួង ស្ថាប័ន និងសាមីជនដែលត្រូវអនុវត្ត) រាជកិច្ច និងឯកសារ កាលប្បវត្តិ។

**ង- ការចុះលេខនិងបោះត្រា** ទីស្តីការគណៈរដ្ឋមន្ត្រីមានភារកិច្ចចុះលេខនិងកាលបរិច្ឆេទលើអនុក្រឹត្យ ហើយបោះត្រាទីស្តីការគណៈរដ្ឋមន្ត្រី នៅតាមជ្រុងរឹមខាងស្តាំនៃអនុក្រឹត្យលើគ្រប់សន្លឹក លើកលែងតែសន្លឹកទំព័រដែលមានហត្ថលេខានាយករដ្ឋមន្ត្រី។

គំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
ឬសម្រេចតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ** :...

**អនុក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការបង្កើត... (ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/... (លេខខែឆ្នាំ)/... (លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី ...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ )
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី... ខែ... ឆ្នាំ... (ក្នុងករណីដែលបានឆ្លងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី) ឬ
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល (ក្នុងករណីតាមឆន្ទានុសិទ្ធិរបស់ប្រមុខរាជរដ្ឋាភិបាល)

## សម្រេច

### ជំពូកទី១

### បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

............................................................................................................................។

### ជំពូកទី២ និង ជំពូកបន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

............................................................................................................................។

### ជំពូកទី...

### អន្តរប្បញ្ញត្តិ (ប្រសិនបើមាន)

**មាត្រា... .-**

............................................................................................................................។

### ជំពូកទី...

### អវសានប្បញ្ញត្តិ

**មាត្រា... .-**

អនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករអនុក្រឹត្យចាស់ទាំងស្រុង) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីអនុក្រឹត្យថ្មី ឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់អនុក្រឹត្យចាស់)

**មាត្រា... .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង... (ឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំ) រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា... (ពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាបទបញ្ញាទូទៅដែលមិនបានឆ្លងអង្គប្រជុំ
ពេញអង្គគណៈរដ្ឋមន្ត្រី តែមានសំណើពីក្រសួង ស្ថាប័នសាមី

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ** :...

# អនុក្រឹត្យ

## ស្តីពី

(ចំណងជើងជាអក្សរមូល)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់... (ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី)

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

................................................................................................................................។

**ជំពូកទី២** និង **ជំពូក**បន្តបន្ទាប់

(ចំណងជើង)

**មាត្រា... .-**

................................................................................................................................។

**ជំពូកទី...**

**អន្តរប្បញ្ញត្តិ** (ប្រសិនបើមាន)

**មាត្រា... .-**

................................................................................................................................។

**ជំពូកទី...**

**អវសានប្បញ្ញត្តិ**

**មាត្រា... .-**

អនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី... និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីនិរាករអនុក្រឹត្យចាស់ទាំងស្រុង) ឬ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។ (ក្នុងករណីអនុក្រឹត្យថ្មី ឬក្នុងករណីនិរាករចំណុចឬផ្នែកមួយចំនួនរបស់អនុក្រឹត្យចាស់)

**មាត្រា... .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង... (ឬប្រធានស្ថាប័នដែលទទួលបន្ទុករៀបចំ) រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

បានយកសេចក្ដីគោរពជម្រាបជូន(គោរមងារ)នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង**...ឬ **ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួង**...ឬ **រដ្ឋមន្ត្រីក្រសួង**...(ឬប្រធានស្ថាប័នសាមី)

(ហត្ថលេខា)

(**ឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា... (ពាក់ព័ន្ធក្រសួង ស្ថាប័នដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃអនុក្រឹត្យស្តីពីការទទួលស្គាល់

△

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ** :...

**អនុក្រឹត្យ**

**ស្តីពី**

(ចំណងជើងជាអក្សរមូល)

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/... (លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីព ...(ដែលពាក់ព័ន្ធ)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា១ .-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានឈ្មោះ...(ជាភាសាខ្មែរនិងជាភាសាបរទេស) សរសេរជាអក្សរកាត់... (ជាភាសាខ្មែរនិងភាសាបរទេស)។

**មាត្រា២ .-**

...(ឈ្មោះគ្រឹះស្ថាន)មានអាសយដ្ឋាន...និងស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣ .-**

... (ឈ្មោះគ្រឹះស្ថាន) ធ្វើការបណ្តុះបណ្តាលកម្រិត... ដែលមានមហាវិទ្យាល័យចំនួន ...៖

- ..............................................................

- ..............................................................។

**មាត្រា៤ .-**

... (ឈ្មោះគ្រឹះស្ថាន)មានក្រុមប្រឹក្សាភិបាល ...។

**មាត្រា៥ .-**

នាយក(ឈ្មោះគ្រឹះស្ថាន)មានភារកិច្ច៖

- ..................................................

- ..................................................។

**មាត្រា៦ .-**

និស្សិត...(ឈ្មោះគ្រឹះស្ថាន)ដែលបានរៀនចប់កម្មវិធីសិក្សា និងទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះផ្តល់ឱ្យដោយ...(ឈ្មោះគ្រឹះស្ថាន) ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណី...(ឈ្មោះគ្រឹះស្ថាន) បំពេញនិងអនុវត្តបានតាមគោលការណ៍និងបទដ្ឋានរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អគ្គលេខាធិការគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងនាយក(ឈ្មោះគ្រឹះស្ថាន) ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចមាត្រា...
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

គំរូទម្រង់នៃអនុក្រឹត្យមានលក្ខណៈជាឯកត្តភូត

(សញ្ញាជាតិដូចក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលបានបោះពុម្ពលើកទី១)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** :...

# អនុក្រឹត្យ

# ស្តីពី

(ចំណងជើងជាអក្សរមូល)

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការបង្កើត...(ឈ្មោះស្ថាប័នសាមី)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ)
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/...(លេខខែឆ្នាំ)/...(លេខ) ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីលក្ខន្តិកៈដោយឡែកនៃ...(ឈ្មោះក្របខ័ណ្ឌរបស់មន្ត្រីសាមី)
- បានឃើញអនុក្រឹត្យលេខ... អនក្រ.បក ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់...(ឈ្មោះក្រសួង ស្ថាប័នសាមី)
- បានឃើញអនុក្រឹត្យលេខ...អនក្រ. ... ចុះថ្ងៃទី... ខែ... ឆ្នាំ... ស្តីពី...(ដែលពាក់ព័ន្ធ )
- យោងតាមសំណូមពរចាំបាច់នៃការងារឬយោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលឬ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួង...(ឬប្រធានស្ថាប័នសាមី) ឬ
- យោងតាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវផ្តល់គ្រឿងឥស្សរិយយស

# សម្រេច

**មាត្រា១ .-**

ចំពោះអនុក្រឹត្យស្តីពីការតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖

ត្រូវបានតាំងស៊ប់លោក ... អត្តលេខ...(បើមាន) ក្នុងក្របខ័ណ្ឌ... ឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានតាំងស៊ប់មន្ត្រីរាជការក្នុងក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... ។

**ចំពោះអនុក្រឹត្យស្តីពីការតែងតាំងមន្ត្រីរាជការដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះអនុក្រឹត្យស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យជំនួសមន្ត្រីរាជការណាម្នាក់ ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា ... ជំនួសលោក... ដែលបានទទួលភារកិច្ចថ្មី(ឬមូលហេតុផ្សេងទៀត)។

**ចំពោះអនុក្រឹត្យស្តីពីការតែងតាំងមន្ត្រីរាជការ ដើម្បីបំពេញមុខតំណែងសមស្របតាមឧបនិស្ស័យសម្រាប់ អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានតែងតាំងលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា... នៅ...។ ឬ

ត្រូវបានតែងតាំងមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ជា...។

**ចំពោះអនុក្រឹត្យស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការឱ្យបំពេញមុខងារក្នុងមុខតំណែងខ្ពស់ជាងឧបនិស្ស័យ សម្រាប់អង្គភាពបង្កើតថ្មី ត្រូវចែងដូចតទៅ៖**

ត្រូវបានប្រគល់ភារកិច្ចជូនលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា... នៅ...។ ឬ

ត្រូវបានប្រគល់ភារកិច្ចជូនមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ឱ្យបំពេញមុខងារជា...។

**ចំពោះអនុក្រឹត្យស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ(ផ្ទៃក្នុង) ត្រូវចែងដូចតទៅ៖**

ត្រូវបានផ្ទេរភារកិច្ចលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង) នៅ...។ ឬ

ត្រូវបានផ្ទេរភារកិច្ចមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ពី...(មុខតំណែង) ទៅជា...(មុខតំណែង)។

**ចំពោះអនុក្រឹត្យស្តីពីការដំឡើងឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរសក្តិលោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ ឬ

ត្រូវបានដំឡើងឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ...។

**ចំពោះអនុក្រឹត្យស្តីពីការដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនលោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដែលបាន... (ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។ ឬ

ត្រូវបានដំឡើងឋានន្តរសក្តិកិត្តិយសជូនមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដែលបាន... (ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... ទៅឋានន្តរសក្តិ... ថ្នាក់លេខ... នៅ... ដែលបាន... (ចូលនិវត្តន៍ ឬលាលែង ឬដាក់ឱ្យឈប់ពីការងារដោយបាត់បង់សមត្ថភាពការងារ ឬទទួលមរណភាព ជាកិច្ចបច្ឆាមរណៈ)។

**ចំពោះអនុក្រឹត្យស្តីពីការបន្ថយឋានន្តរសក្តិមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយឋានន្តរសក្តិលោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានបន្ថយឋានន្តរសក្តិមន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ពីឋានន្តរសក្តិ... ថ្នាក់លេខ... មកឋានន្តរសក្តិ... ថ្នាក់លេខ... នៅ.... ដោយមូលហេតុ...។

**ចំពោះអនុក្រឹត្យស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការតាមវេនជ្រើសរើសនិងវេនអតីតភាព ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ...។ **ឬ**

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ចាប់ពីថ្ងៃទី១៣ ខែមេសា ឆ្នាំ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះអនុក្រឹត្យស្តីពីការដំឡើងថ្នាក់មន្ត្រីរាជការ ដែលទទួលបានសញ្ញាបត្រខ្ពស់ជាងការកំណត់ក្នុងក្របខ័ណ្ឌ ត្រូវចែងដូចតទៅ៖**

ត្រូវបានដំឡើងថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព។ **ឬ**

ត្រូវបានដំឡើងថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ...ដោយរក្សាទុកអតីតភាពសម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើសនិងវេនអតីតភាព ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... ទៅថ្នាក់លេខ... នៅ...។

**ចំពោះអនុក្រឹត្យស្តីពីការបន្ថយថ្នាក់មន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបន្ថយថ្នាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ដោយមូលហេតុ...។ **ឬ**

ត្រូវបានបន្ថយថ្នាក់មន្ត្រីរាជការនៃក្របខ័ណ្ឌ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ពីថ្នាក់លេខ... មកថ្នាក់លេខ... នៅ... ដោយមូលហេតុ...។

**ចំពោះអនុក្រឹត្យស្តីពីការដកមន្ត្រីរាជការពីមុខតំណែង ត្រូវចែងដូចតទៅ៖**

ត្រូវបានដកលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចេញពីមុខតំណែង... ដោយមូលហេតុ... ។ **ឬ**

ត្រូវបានដកមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចេញពីមុខតំណែង... ដោយមូលហេតុ...។

**ចំពោះអនុក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

២- លោក ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ដើម្បី...។

**ចំពោះអនុក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម។

**ចំពោះអនុក្រឹត្យស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... (តាមសំណើឬដោយមូលហេតុ...)។

**ចំពោះអនុក្រឹត្យស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារឡើងវិញ ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឱ្យលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។ ឬ

ត្រូវបានអនុញ្ញាតឱ្យមន្ត្រីរាជការនៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។

២- លោក ... អត្តលេខ... (បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... ចូលបម្រើការងារឡើងវិញ ដោយទទួលមុខតំណែង...(បើមាន) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ... ក្រោយពេលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សរយៈពេល...។

**ចំពោះអនុក្រឹត្យស្តីពីការបញ្ចប់ភារកិច្ចមន្ត្រីរាជការ ត្រូវចែងដូចតទៅ៖**

ត្រូវបានបញ្ចប់ភារកិច្ចលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ (បើជាមន្ត្រីមានក្របខ័ណ្ឌ)។ ឬ

ត្រូវបានបញ្ចប់ភារកិច្ចមន្ត្រីរាជការឱ្យទៅបម្រើការងារនៅស្ថាប័នដើមវិញ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (បើជាមន្ត្រីមានក្របខ័ណ្ឌ)។

**ចំពោះអនុក្រឹត្យស្តីពីការលុបឈ្មោះឬបញ្ឈប់មន្ត្រីរាជការពីការងារ ត្រូវចែងដូចតទៅ៖**

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។ ឬ

ត្រូវបានលុបឈ្មោះឬត្រូវបានបញ្ឈប់មន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ...នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ដោយមូលហេតុ...។

**ចំពោះអនុក្រឹត្យស្តីពីការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះអនុក្រឹត្យស្តីពីការអនុញ្ញាតឬការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ត្រូវចែងដូចតទៅ៖**

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... ឱ្យចូលនិវត្តន៍មុនកំណត់ (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានអនុញ្ញាតឬត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនកំណត់ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ... (តាមសំណើរបស់សាមីខ្លួនឬដោយមូលហេតុ...) ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះអនុក្រឹត្យស្តីពីការដាក់មន្ត្រីរាជការដែលកាន់តំណែងនយោបាយឱ្យចូលនិវត្តន៍ ត្រូវចែងដូចតទៅ៖**

ត្រូវបានដាក់លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈដោយរក្សាមុខតំណែងនយោបាយ ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។ ឬ

ត្រូវបានដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ដោយរក្សាមុខតំណែងនយោបាយ ដូចមានរាយនាមខាងក្រោម៖

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

២- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... នៅ... ចាប់ពីថ្ងៃទី... ខែ... ឆ្នាំ...។

**ចំពោះអនុក្រឹត្យស្តីពីសមាហរណកម្មមន្ត្រីរាជការក្នុងក្របខ័ណ្ឌប្រភេទ ខ ត្រូវចែងដូចតទៅ៖**

ត្រូវបានធ្វើសមាហរណកម្មលោក...ទៅក្នុងក្របខ័ណ្ឌ...ឋានន្តរសក្តិ...ថ្នាក់លេខ...អត្តលេខ...(បើមាន) នៅ...។ ឬ

ត្រូវបានធ្វើសមាហរណកម្មមន្ត្រីរាជការទៅក្នុងក្របខ័ណ្ឌ... នៅ... ដូចមានរាយនាមខាងក្រោម៖

១- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

២- លោក ... ឋានន្តរសក្តិ... ថ្នាក់លេខ... អត្តលេខ...(បើមាន)។

**ចំពោះអនុក្រឹត្យស្តីពីការផ្តល់គ្រឿងឥស្សរិយយស ត្រូវចែងដូចតទៅ៖**

ត្រូវបានបំពាក់គ្រឿងឥស្សរិយយស...(ឈ្មោះ) ថ្នាក់...(កម្រិត)ជូនលោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ... មុខតំណែង... នៅ...។ ឬ

ត្រូវបានបំពាក់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោម៖

ក- គ្រឿងឥស្សរិយយស...(ឈ្មោះ) ថ្នាក់...(កម្រិត)

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ...មុខតំណែង... នៅ...។

២- ...។

ខ- គ្រឿងឥស្សរិយយស...(ឈ្មោះ) ថ្នាក់...(កម្រិត)

១- លោក ... អត្តលេខ...(បើមាន) ឋានន្តរសក្តិ... ថ្នាក់លេខ... នៃក្របខ័ណ្ឌ...មុខតំណែង... នៅ...។

២- ...។

**មាត្រា២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

(មាត្រានេះមិនត្រូវចែងទេ ក្នុងករណីជាក់ស្តែងដែលមិនតម្រូវឱ្យនិរាករលិខិតបទដ្ឋានគតិយុត្តមុនៗដែលពាក់ព័ន្ធ)

**មាត្រា៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង... (ឬប្រធានស្ថាប័នដែលស្មើ) រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី... ខែ... ឆ្នាំ...

**នាយករដ្ឋមន្ត្រី**

(ហត្ថលេខានិងត្រា)

(**គោរមងារនិងឈ្មោះ**)

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ(គោរមងារ)នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ(គោរមងារ)ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា... (ពាក់ព័ន្ធក្រសួង ស្ថាប័ន និងសាមីជនដែលត្រូវអនុវត្ត)
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



(*តទៅ រាជកិច្ចលេខ ៤៩*)